កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ហួត-តាត
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ជីរឿង	ទំព័រ
តាំងនេត្រ-ឡាំងសី	របរថ្នាំជក់	៣២១
លោក ភ័យ-ប៊ុក ក្រមការ	សុភាសិត ភាគ ១ (តមក)	៣៣១
—	ប្រជុំពាក្យព្រេងនិងបារបនាបារាំង (តមក)	៣៣៥
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម	សព្ទបារាំង ប្រែជាខ្មែរ	៣៤១
—	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក)	៣៤៥
អ្នកឧកញ៉ា ឌូ-កន	រឿងសាមកុក (តមក)	៣៥៣

ផ្នែកសាសនា

ព្រះបាឡាត់ សុង-ស៊ីវ	ត្រៃភូមិធម៌	៣៦៣
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម	ពង្សអាស៊ីទ្វីប (តមក)	៣៧៥

កំណត់ទីនប្រវត្តិការណ៍

ភិក្ខុ ឡេង-ឈួន	ប្រវត្តិព្រះមហារស់-កោ	៣៨១
ភិក្ខុ សួន-ស៊ីវ	បុណ្យបូជាសពអ្នកអាចារ្យហ៊ុន-សុង (តមក)	៣៨៦
ក្រសួងធម្មការ	អំពីការតាំងហៅអធិការថ្មី (តមក)	៣៩៥

ឆ្នាំទី ២១ – លេខ ៥ ខែឧសភា ឆ្នាំ ១៩៤៩ – ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

page

Néang Net-Langsey — Culture du tabac au Cambodge.. ... 321

M. Ray-Buc kramakar (I. B.) — Proverbes et maximes tome I (suite). 331

—id— Recueil de Dictons et devises français (suite)..... 335

Luong Nibandhamantrî Nhok-Thêm — Version 341

—id— Histoire sommaire de l'Inde (suite). 345

Neak Oknha Nou-Kan — Histoire de «Sam-Kok» (suite de N°3) 353

Partie religieuse:

Vén. Brah Balat Song Siv — Trai Kûdadharma..... 363

Luong Nibandhamantrî Nhok-Thêm — Lumière de l'Asie (suite)..... 375

Notes et chroniques

Vén. Léng-Chhour — Biographie du Vén. Brah Maha Ros-Ko 381

Véd. Suon-Surin — Compte-rendu sur les cérémonies de crémation de l'Achar Hin-Such (suite)..... 386

Ministère des cultes — Nomination des nouveaux chau Adhikar (suite)..... 395

21e Année: N° 5 Mai 1949 — Prix d'abonnement: 96$00 par an.

របរថ្នាំ

របស់នាង ខេត-ឡាំងសី

នៅភូមិបឹងកេងកង ឃុំលេខ ៦ ក្រុងភ្នំពេញ

(រង្វាន់លេខ ១)

របរថ្នាំជារបរធំ ១ មុខ នៅប្រទេសកម្ពុជា ប្រហែលគ្នានឹងរបរស្រូវ ហើយជាកេសដ្ឋៈមួយយ៉ាង ដែលប្រជាជនក្នុងលោកត្រូវការបរិភោគរៀងៗ ស្ទើរតែគ្រប់រូប ។ របរនេះជារបរធ្វើបានដោយនឿយហត់លំបាកជាងរបរស្រែចម្ការទាំងពួង ទោះបីធ្វើតិចក៏ត្រូវមានកម្មករយ៉ាងតិចត្រឹម ៤-៥ នាក់ទើបបាន តែអ្នកខេត្តចូលចិត្តធ្វើច្រើនស្រុក ព្រោះជារបរមានដំឡៃច្រើន ស្រុកស្រែក៏ធ្វើបានដែរ តែពុំបានច្រើនដូចស្រុកខេត្ត ដោយដំណាំនេះត្រូវតែនឹងដីខេត្តជាកោះ ឬត្រើយ ដែលមានទឹកលិចរាល់ឆ្នាំ មានល្បាប់ហាក់ជាច្រើនក្នុងរដូវភ្លៀង ។ នៅប្រទេសកម្ពុជានេះ ស្រុកដែលធ្វើរបរថ្នាំច្រើន គឺស្រុកនៅតាមឆ្នេរមាត់ទន្លេមេគង្គទាំងសងខាង គឺពួកកោះខ្សាច់កណ្ដាល ត្រើយកោះកោង ព្រែកកុយ ស្រុកមុខកំពូល ត្រើយអង្គរបាន ស្រុកកងមាស ពួកកោះអណ្ដែត កោះសូទិន ស្រុក-កោះសូទិន កោះកុក កោះប្រាក់ កោះប៉ែន កោះកំពង់ត្រំ ពួកកោះសំរោង កោះលួង កោះជ្រុក ស្រុកកំពង់សៀម ត្រើយក្រូចឆ្មារ ស្រុក-ក្រូចឆ្មារ ។ល។ ស្រុកអំបាលនេះ នៅក្នុងខែត្រកំពង់ចាម ។

បណ្តាស្រុកទាំងនេះ មានតែស្រុកក្រូចឆ្មារមួយទេដែលល្បីឈ្មោះជាងគេខាងធ្វើថ្នាំសរសៃធ្មារ ។

វេលានេះ សូមរាប់រៀបរាប់ពីរបៀបធ្វើរបរថ្នាំតាមទំនៀមអ្នកកោះអណ្តែតតូច ស្រុកកងមាស នៃខេត្តកំពង់ចាម ដូចតទៅនេះ ៖

លំដាប់ថ្នាក់របរថ្នាំ

របរថ្នាំ មានលំដាប់ថ្នាក់ត្រូវធ្វើ ១២ ថ្នាក់គឺ

១ – សាប ៧ – បន្ទុំស្លឹក

២ – ស្ទូង ៨ – ហាន់

៣ – ដាំ ៩ – ហាល

៤ – ជ្រឹង ១០ – យកសន្សើម

៥ – ក្តិចត្រួយក្រៀវខ្នង ១១ – បក់ថ្នាំ ឬ ចាញ់ត្រាំ

៦ – កាច់ស្លឹករៀបស្លឹក ១២ – រៀបញុក ឬ ដាក់ឆាល

១ – សាប

របរថ្នាំកង ១ ឆ្នាំធ្វើបានតែម្តងទេនៃប្រាំង ព្រោះដំណាំនេះជាសត្រូវនឹងភ្លៀង តែទោះបីដូច្នោះ ក៏ត្រូវតែចាប់ផ្តើមធ្វើជាដំបូង តាំងពីចុងរដូវភ្លៀងគឺខែអស្សុជ (តុលា = អុកតូប្រ) ទល់នឹងដើមរដូវភ្លៀងគឺខែជេស្ឋ (មិថុនា = យូអាំង) ទើបរួចស្រេចសព្វគ្រប់ ។ តាមទំនៀមអ្នកស្រុកកោះអណ្តែតដែលជាស្រុកមានទឹកទន្លេលិចជ្រៅ ដល់ចុងរដូវភ្លៀងទឹក

ស្រុកទៅនៅមានកក់ល្បាប់ គេតែងទៅរកស្រុកត្រើយត្រង់ណា ដែលមានដីព្រៃមានដំណួ ហើយនៅជិតមាត់អូរឬបឹង មានទឹកមាន គុម្ពឫស្សី-ឈើ-ត្រែង-រលុំ-រុន ដែលអាចរកគ្រឿងប្រដាប់ សាបកូនចាំ បានងាយធ្វើជាទីសាបកូនចាំ ។ កាលបើបានហើយគេមើលឫក្សថ្ងៃ តាមក្បួនជយោសុខោ ដោយគិតតាមឆ្នាំអ្នកម្ចាស់ការ ហើយគេធ្វើស្វាធមិ ឆាងបេក ១ គូ គឺកាត់ឆាងបេកប្រវែង ៤ ធ្នាប់ ដោតមុំ ៣ សន្ទឹកនៅចុង ឆាងបេកម្ខាងជា ៣ ជ្រុង ដោតផ្លែស្វា ១ ចំកណ្ដាលចុងឆាងបេកនោះ ហើយដោតបញ្ឈរកឫស្សីធ្វើជើង ៣ អុជទៀន ១ ធូប ៣ កន្ទុះ ថ្វាយទេ-វតាបុរាណអ្នកតាជាម្ចាស់ព្រៃនោះ និយាយសុំព្រៃធ្វើជាទីសាបកូនចាំក៏មាន អ្នកខ្លះគ្រាន់តែអុជទៀន ១ ធូប ៣ កន្ទុះក៏មាន អ្នកខ្លះមិនធ្វើដូច្នោះក៏មាន រួចហើយគេផ្ដើមកាប់ព្រៃទឹងដីនោះ ធ្វើរងចាំដោយគ្រឿងប្រដាប់អំបាល នេះគឺ :

ក) ត្បូងថៅ មានផ្លែដែក បណ្ដោយ ១ តោម ទទឹងក្បាល ៣ ធ្នាប់ មុខ ៤ ធ្នាប់ ក្បាលក្រាស់ មុខស្ដើង មានប្រហោងត្រង់ក្បាល ហៅថា "ឈៅ" ស៊កដងឈើទំហំប៉ុនកដៃ រាងសំប៉ែត បណ្ដោយ ១ ហត្ថទៅក្នុង "ឈៅ" នោះ (តាមច្បាប់ដើមមានត្បូងថៅផង) ។

ខ) កាំបិត មានផ្លែដែក បណ្ដោយ ១ តក់ ទទឹងគល់ ២ ធ្នាប់ ចុង ៤ ធ្នាប់ ខ្នងក្រាស់ប៉ុនខ្នារ មុខស្ដើងដូចស្លឹកស្រូវ មៀនដែកមូលប្រ-

ហោង ប្រវែង ២ ម្រាប់ ទទឹង ២ ម្រាប់, ដងឈើបុតាងតាមមូលប៉ុនកដៃ ក្នុង ប្រវែង ២ ម្រាប់, គល់ផ្ទៃមានទម្រ ស៊ីកម្ពាប់ទៅក្នុងមៀនហ៊ីយនឹងដី (តាមច្បាប់ដើមមានគូរូបកាំបិតផង) ។

គ) ចបកាប់ មានផ្ទៃដែក ប្រវែងណាយ ១ បំភាម ទទឹង ១ ទោម ក្រមាស់ប៉ុនខ្នារ ចុងប៉ុនមុខកាំបិត ត្រង់ក្បាលបំកណ្តាលមានប្រហោងសម្រាប់ស៊ីកដង ប្រវែង ២ ហត្ថ ធ្វើពីឈើបុតាងតាមប៉ុនកដៃក្នុង (តាមច្បាប់ដើមមានគូរូបចបកាប់ផង) ។

ឃ) ចបដ៏ក មានផ្ទៃដែកបណ្តាយ ១ ទោម ទទឹង ៥ ម្រាប់ ក្រមាស់ប៉ុនខ្នារ ចុងប៉ុនមុខកាំបិត ក្រាស់ដូចស្រទាបចេក ដងឈើបុតាងតាមប៉ុនកដៃក្នុង ប្រវែង ២ ហត្ថ ត្រង់ក្បាលមានប្រហោងសម្រាប់ស៊ីកដង (តាមច្បាប់ដើមមានគូរូបចបដ៏កផង) ។

ង) ១ទោសដៃ ធ្វើពីដែកបុរណើ មានមេទំហំ ៣ ម្រាប់ ៤ ត្រង់ ១ផ្ទាំសំបែតបន្ថែម ប្រវែង ១ ហត្ថ មានផ្ទេញ ៦ ឬ ៨ គល់ផ្ទេញប៉ុនក្រមាដៃ ចុងស្រួចប្រវែង ១ ទោម ដងឈើប៉ុនកដៃ ប្រវែង ២ ហត្ថ (តាមច្បាប់ដើមមានគូរូប១ទោសដៃផង) ។

ច) អន្ទង់ ក្ងន់ណើ ឬ ពាងតាង ទំហំប៉ុនកដៃ ប្រវែងណាយ ១ ហត្ថ (តាមច្បាប់ដើមមានគូរូបអន្ទង់ផង) ។

ធ) ចាំងទឹកធ្វើពីឈើ ទំហំមាត់ ១ ចំណាមកន្ទុះ ចាត់ពាងតូចបន្តិចជាងមាត់ ពាងមូលមានខ្ទង់សម្រាប់ពាក់ខ្សែរែកទឹក (តាមច្បាប់ដើមមានគូរក្បូចចាំងទឹកផង) ។

ជ) ហ្គោយត្រនេឡាក ធ្វើពីត្រនេឡាកដូង ចោះចាត់ប្រហោងតូច ៗ ញ៉ីកស្អេក មានផងប៉ុនមេដៃស៊ីកតាមចំណោះត្រង់មាត់ពីម្ខាងទៅម្ខាង(តាមច្បាប់ដើមមានគូរក្បូចហ្គោយត្រនេឡាកផង) ។

គេកាប់ឈើដោយតូចៗ កាប់ឫស្សី - ត្រែង - ទ្រ ងវ្ស ដោយកាំបិតកាប់គាស់ដោយចបកាប់ កាស់គាយដោយខ្មោសដៃ ពាយបំបែកដោយអន្ទង ពួនដាតំនូកជារង្វង់ឲ្យខ្ពស់ជាងដីធម្មតា កំពស់ចំនួន ៥ ផ្ទាប់ហៅว่า "រង្ចាំ" បណ្ដាយប្រវែង ២ ព្យាមដៃ ទទឹង ២ ហត្ថ ធ្វើឲ្យរាបស្មើដូចផ្ទៃស្ពារ ឲ្យមានចំណោមខ្ពស់ទាន ។ ដុំវ ញ ស៊ីសយកកំទេចស្មៅ-ឈើចេញអស់ ហើយដ៏ងដ៏ងទៅហាមរង ដុំវ ញ ដោយចបជីក ដាំបង្គ្រាលឃ្លាតពីគ្នា ២ ព្យាមដៃ ចងគ្រោងទទឹងរង ពីបង្គ្រាលម្ខាងទៅម្ខាង យកនាបប្ដូកមួយ ចងបណ្ដាយរង ដោយស្ងួតប្រាក់ត្រែងឡ ស្ដើង ។ ធ្វើជាដំបូលការពារកុំឲ្យក្ងៀងស្រក់ចោះដ ហើយគេដងទឹកដោយចាំង ស្រោចដំ រង្ចាំ ខ្មោះដោយហ្គោយឲ្យទទឹកជ្រាកសព្ទ ទុកឲ្យស្រាប់ បន្ទាប ទើបគេយកគ្រាប់ពូជ ច្ចាំ ដែលមានគ្រាប់ល្អ ។ ប៉ុនគ្រាប់ស្ដ ដែលខ្ជ ប់ កំណាត់ សំពត់ គ្រ ទឹកហ្ការ ១ ថ្ងៃ ផ្ទាប់ ១ ១ ២ - ៣ យ ប ឲ្យ ហ ម ប្រ ះ គ្រ ប

យើញសាបន្តិចៗ មកសាបវាយស្មៅពេញរនាំហើយគេយកផែនល្អិតធំវាយ ស្ពឹងៗ ពីលើគ្រាប់ចាំនោះ ដើម្បីការពារស្រមោចលាន ដូនកាលគេ លាយផែន ១ ភាគ គ្រាប់ចាំ ៣ ភាគ ច្រមាលជាមួយគ្នាជាមុន ហើយទើប គេយកទៅសាបកំមាន ។ គេសាបចុះ ១ រង្គហើយ ធ្វើរង្គសាប ១ រង្ គ ទៀត ក្បែរៗ គ្នា ៤-៥ រង្ ឲ្យល្មមតាមចំនួនដែលគេត្រូវការ ។ លុះ សាបហើយគេស្រោចស្រស់ទឹកត្រីត-ល្ងាច ឲ្យដីនៅសើមជានិច្ច ។ ក្រោយពីសាប ២-៣ ថ្ងៃ ក្ងានសំណាបនោះ ក៏ដុះបែកស្លឹកធំឡើងតាមលំ-ដាប់លុះដល់ធំប៉ុនក្ងាក់ក្ងាត់ គេយកដីដីអាចម៍មានតាក្រាមធ្ងន់ មកវាយ ឲ្យល្អិតម៉ដ្ឋទៅពេយស្ពឹងៗ លើកូនចាំ ហើយស្រោចទឹកសង្កត់ ។ ចាប់ ដើមពីនោះមកគេស្រោចរាល់ថ្ងៃ ដោយទឹកលាយទឹកមូត្រមនុស្ស-គោ-ក្របី ដែលគេត្រង់ទុកយូរមានកូនស្អុយ លាយទឹក ៧-៨ ភាគ ទឹកមូត្រ ១ ភាគ ។ នៅពេលធ្វើកូនចាំ អ្នកធ្វើរបរនេះគេសំចៃទឹកមូត្រមិនហ៊ាន ចោលទេ ។ កូនចាំនោះលុះត្រូវដ៏ទឹកដ៏ធ្ងន់ធ្ងរ ក៏លូតលាស់យ៉ាង រហ័ស ។

កាលកូនចាំមានស្លឹកធំជាង ក្ងាក់ក្ងាត់ឡើងទៅ គេរុះដំបូលចេញ ដើម្បីឲ្យត្រូវចំហាយថ្ងៃ តាំងពីថ្ងៃសាបមកជាង ១ ខែ កូនចាំក៏មានស្លឹក ប៉ុនក្ងាក់រៀល ។

២ — ស្ទូង

កាលកូនច្នាំសំណាបមានស្លឹកធំប៉ុនប្រាក់រៀលហើយ គេដកចេញពីរងសំណាបយកទៅស្ទូង លើរងសំទូងនៅក្បែរគ្នានោះ ។ មុននឹងដកកូនសំណាបទៅស្ទូង គេស្រោចទឹកកូនច្នាំក្នុងរងសំណាបឲ្យជោកសព្វ ហើយគេរើសដកយកតែកូនសំណាបណាដែលមានកំពស់ ៣-៤ ធ្នាប់ គេលាស់ដីដែលជាប់នឹងឫសចេញខ្លះ រួចគេយកទៅស្ទូងលើរងសំទូង ក្រោយដែលគេស្រោចទឹកជ្រមដីរងនោះស្រេចហើយ ។

របៀបស្ទូងគេយកមែកឈើឫស្សីតូចប៉ុនកូនមេដៃ ចុចទៅលើដីរងដោយដៃឆ្វេង ហើយគេចាប់កូនច្នាំដោយដៃស្តាំ យកគល់កូនច្នាំញាត់ទៅក្នុងចំណុចរណ្តៅ ហើយយកដៃបិទដីគល់កូនច្នាំ គេស្ទូងឲ្យឃ្លាតពីគ្នា ៣-៤ ធ្នាប់ ។ តាំងពីស្ទូងហើយមានកំប្រុងត្រូវថែរក្សាដោយស្រោចទឹកដីដាក់ដីជីបន្ថែមដូចកាលនៅជាកូនសំណាប ។ ដល់កូនសំទូងដុះស្រស់ល្អមានដើមរឹងប៉ឹងទៀង គេបើកដំបូលចេញឲ្យត្រូវកំដៅថ្ងៃ ។ តាំងពីថ្ងៃស្ទូងមកចំនួនជាង ១ ខែ កូនសំទូងធំមានស្លឹកម្លូលពងទទែងទទឹង ៣-៤ ធ្នាប់ បណ្តោយ ៥-៦ ធ្នាប់ ដើមប៉ុនខ្ទារ កំពស់ពីគល់ដល់ចុងសន្ទឹក ១ ហត្ថ ១ ចំអាម ល្មមដកយកទៅដាំក្នុងចម្ការបាន ។

របៀបធ្វើកូនច្នាំដែលមានសាបមានស្ទូងដូច្នេះ ជារបៀបសម័យ

បុរាណ ឯសម័យបច្ចុប្បន្ននេះគេមិនបាច់ស្ទូងទេ គ្រាន់តែសាបហើយ គេទុកកូនសំណាបនោះឲ្យធំល្មមដាំបាន ទើបគេដកយកទៅដាំតែម្តង ។

៣– ដាំ

កាលដល់បុណ្យខែកត្តិកឬដើមខែមិគសិរ (ធ្នូ ដេសម្ប្រ៍) ដែលកូនថ្នាំមានទំហំធំប៉ុនដែលពោលមកក្នុងថ្នាក់ទី ២ ខាងដើមនោះ ត្រូវនឹងពេលដីចម្ការ ក៏ទឹកទើបនឹងស្រកផុតទៅថ្មីៗ ដីនៅសើមល្អ អ្នកធ្វើរបរចំការគេទៅធ្វើដីចម្ការ ៗ របៀបធ្វើដីចម្ការគេធ្វើត្រង់ក្បាលចម្ការមុន គឺមុនដំបូងគេកាប់ព្រៃត្រង់ស្មៅផុតចោល ហើយភ្ជួររាស់ដីធ្វើជាទីដាំកូនថ្នាំដោយត្រៀមប្រដាប់អំបាលនេះ គឺ :

ក) ខ្វែរត្រង់ មានដៃដែកប្រវែង ១ ហត្ថទទឹង ៤ ធ្នាប់ កក្រង់ក មៀនដែកប្រវែង ៣ ធ្នាប់ មានទន្សាត្រង់ស៊កទៅក្នុងដងឈើប្រពីងពង់ប៉ុនកដៃ វែង ប្រវែង ២ ហត្ថ ១ ចំអាម ។ (ប្លាប់ដើមមានគូររូបខ្វែរត្រង់ផង) ។

ខ). ខ្វែរបក មានដៃដែកប្រវែងជាង ១ ចំអាម ទទឹង ៥ ធ្នាប់ មៀនដែកប្រវែង ៣ ធ្នាប់ មានទន្សាក្រង់ក មានដងទំហំនិងប្រវែងប៉ុនខ្វែរត្រង់ៗ (ប្លាប់ដើមមានគូររូបខ្វែរបកផង) ។

គ) រនាស់ធំ មានមេឈើ ៤ ជ្រុង រាងសំប៉ែតបន្តិច ទំហំទោល ៤ ធ្នាប់ បន្ទា ៥ - ៦ ធ្នាប់ ប្រវែង ៤ ហត្ថ ធ្មេញឈើខ្លឹម ចំនួន ៨ ឬ ១០ ប្រវែង ១ តឹក ទំហំ ២ ធ្នាប់ គល់ ៤ ជ្រុង ចុងមូលស្រួច ស៊កទៅក្នុង

ដំណាប់មេ, ដងឈើប្រវែង ៦ ឬ ៧ហត្ថ គល់ដងជ្រុង ចុងមូលកងសំប៉ែតបន្តិច គេបោះដងត្រង់កងាក់គិល មានទឹមឈើឬឫស្សីប៉ុនកំភួនជើង ប្រវែង ៤ ហត្ថ ចងភ្ជាប់ទឹមដងដោយខ្សែព្រាមធ្វើពីស្បែកគោឬផ្តៅវេញ មានខ្សែទាម ២ ត្បាញកណ្តាល វេញចុង-ដើមដោយផ្តៅ ចងភ្ជាប់ទឹម ទឹម ១ ម្នាង សម្រាប់ទឹមគោ ២ ហៅថា ១ ទឹម ។ (ច្បាប់ដើមមានគូររូបនាសធំព្រមទាំងទឹមផង) ។

ឃ) នង្គ័ល មានក្រៀងឈើ មុខស្រួច មានធ្មេញងាក់ងាល ដែកក្រោយមានស្លាបជាចំពាម បណ្តោយប្រវែងជាង ១ ហត្ថ ទទឹងស្លាបបញ្ឈរ ១ ទោម មានកន្ទុយកង ២ ជ្រុងសំប៉ែតបន្តិច ទំហំ ៤ ឬ ៥ ធ្នាប់ ត្រង់កន្ទុយមានដំណាប់សម្រាប់បញ្ចុះយាមឈើកងមូលគោង ប្រវែង ៣ ហត្ថ ។ (ច្បាប់ដើមមានគូររូបនង្គ័លផង) ។

ង) គប់ មានផ្លែឈើមូលប៉ុនក្តោ ប្រវែងជាង ១ ចំអាម ដងឈើមូលប៉ុនកដៃ ។ (ច្បាប់ដើមមានគូររូបគប់ផង) ។

ច) ឈើបុះ ទំហំប៉ុនកំភួនដៃ ប្រវែង ៤ ហត្ថ វៀងចុងស្រួចគល់ ។ (ច្បាប់ដើមមានគូររូបឈើបុះផង) ។

ឆ) ខ្សែសំង មានដងឫស្សី ២ ទំហំដំណាងមេដៃ ប្រវែង ១ ហត្ថ ១ តក់ ចងខ្សែ ១ ចន្លាយភ្ជាប់ពីដង ១ ទៅដង ១ ប្រវែងខ្សែតាមចំនួនទទឹងបង្ការ ។ (ច្បាប់ដើមមានគូររូបខ្សែសំងផង) ។

គេកាប់ព្រៃត្រែងដោយខ្វែវត្រែង បកស្មៅដោយខ្វែវបុក កាស់ត្រែងទីងស្មៅដោយរនាស់ ភ្ជួរដីដោយនង្គ័ល កាយដីដុំៗដោយគប់ ហើយគេកាស់ដីដោយរនាស់ បន្ទ្រាបដីឲ្យរាបស្មើ ៗ លុះធ្វើដីបានស្រួលបួលហើយ គេផ្ដើមដាំកូនចាំងំបុងដៃនៅថ្ងៃសៅរ៍ ព្រោះមានគន្ធពម្រាដាំដំណាំប្រាប់ថា បើដាំដំណាំយកស្លឹកត្រូវដាំថ្ងៃនេះ តែអ្នកខ្លះគេផ្ដើមដាំតាមក្បួនជយោសុទោនុបតោលមកក្នុងប្រាក់ទី ១ ក៏មាន, អ្នកខ្លះគេដាំដោយមិនបាច់មើលឫក្សថ្ងៃក៏មានដែរ វេលាដាំកូនចាំគេតតមានរបៀបសំណាន់អ្វីទេ គ្រាន់តែមើលឫក្សថ្ងៃប៉ុណ្ណោះឯង ។ មុនទីងដាំ ១ ថ្ងៃ គេទៅស្រោចទឹកកូនចាំនៅរងសំនួង ហើយជ្រើសដកយកតែកូនចាំណាដែលមានទំហំធំប៉ុនដៃលទំយាយក្នុងប្រាក់ទី ២ នោះដាក់ដាលបូល្អជ្រមទឹកគ្រប់ចំទប៉ាំងទុកបម្រុងតាំលាច ដល់ស្អែកឡើងវេលាថ្ងៃរសៀលគេយកខ្សែស៊េះទៅទាញសន្ទឹងទទឹងបម្ភារពីព្រំម្ខាងទៅម្ខាង ដោតបង្គោលខ្សែស៊ីទ ហើយយកឈើបុះ ចុះដីតាមជួរខ្សែស៊ីទនោះឃ្លាតពីគ្នាប្រវែង ១ ហត្ថ ១ ចំអាម ប៉ុន ១ ជួរហើយគេចុះ ១ ជួរទៀត ឃ្លាតជួរពីគ្នាប្រវែង ១ ហត្ថ ១ តក ក៏គេយកឯងខ្សែស៊ីទនោះជាន្ទាត ៗ លុះចុះរណ្ដៅហើយ គេយកកូនចាំទៅដាំក្នុងរណ្ដៅនោះហើយគេលុបដីបន្តិចៗ គ្រប់ឫសកូនចាំ អ្នកខ្លះដាំទៅមុខ អ្នកខ្លះស្រោចទឹកតាមក្រោយដោយកូនក្អម ១ គូប ។

(នៅមានត)

លោកកែយ-ប៊ុក រៀបរៀង (តមក)

៣ – ញាណវគ្គ

៣០– ពូជខ្លាមិនដែលចាកចោលព្រៃ មច្ឆាជលស័យមិនចោលទឹក ពូជចោរមិនចោលចោរកម្ម ជនពាលប្រមឹកមិនចោលខ្ចួច ។

៣១– ពេលគ្រូមានឧស្សាហ៍ កើតទុក្ខចិត្តប្រែជាថ្នាំ ពេលក្រលំបាកខន្តីទ្រាំ ចិត្តពាលប្រាជ្ញាគ្មានថ្នាំកែ ។

៣២– មនុស្សយើងសព្វថ្ងៃ ហ៊ានគោរស័យ ធំស្មោះអោពល ជាតិខ្លាពងស៊ីហ៍ ប្រឹងស្ទៀតគ្រប់កាល មិនចោលក្បួនពាល ចាំចាប់បរិភោគ ។

៣៣– រនាធលុទ ក្មេងផ្ទាក់ប្រាំងមុខ ល្អជាអាក្រក់ ធំទៅជាតួប ពាលឡើងយសសក្តិ មិនខំប្រាជ្ញប្រាក់ ឈើក្រាក់ផុះត្រយ ។

៣៤– គ្រឹហាប៉ាក់បែកនាប់វប់វល់ កុមារល្ងង់សល់គាប់ប្រែលប្រែ បើទុកយូរថ្ងៃកាន់ម៉ាំទៃ ចិត្តពាលពេលកែលំបាកក្រៃ ។

៣៥– សម័យបច្ចុប្បន្នពាលច្រើនភាព សាសនាគួរប្រាបឲ្យបៀសចេញ វិលចុះវិលឡើងជួបពាលពេញ ខ្ទើមទុក្ខទោសមិញគង់តែជួប ។

៣៦– ក្មេងជាតិត្រូវពាក់ពីគ្រូចាប មនុស្សជាតិគេអាចពាក់ពីក្មេង សិក្សាវិជ្ជាត្រូវខ្នះខ្នែង ឲ្យចាំជាក់ស្តែងពីដំបូង ។

៣៧ — ពាលស្គាល់ខ្លួនឯងថាពាលពិត បណ្ឌិតពោលថា ជាប្រាជ្ញបាន បើពាលអួតគុណដែលមិនមាន កុំស្មានរួចខ្លួនពីពាល ឡើយ ។

៣៨ — ជាតិពាលឃើញពាលចូលគ្នាបាន ជាតិសំគាល់ប្រាណ មិនចំគ្នា ពួកចោរយកចោរជាមិត្តភា បណ្ឌិតសោភាគប់សប្បុរស ។

៣៩ — អាចារ្យប្រែចិត្តជាអាចោរ ខ្លួនទំមែកពោធិ៍ស៊ីផ្លែផ្លែ ទុច្ចរិតនាំខ្លួនឲ្យហិនហោ អាស្រ័យសុចរិតកើតសុខា ។

៤០ — ក្អែកស្គាល់ខ្លួនក្អែក គង់ប្រែតាមផ្នែក ជាហង្សវិញ គោ ជាពងស៊ីហ៍ ខុសត្រម្ដេចមិញ ល្ងង់ចូលក៏ចេញ ពេញជាល្ងង់ពិត ។

៤១ — ទ្រព្យពាលប្រយោជន៍រូបគេគ្នា ទ្រព្យសប្បុរសាសាសនា ជាតិ ដូចទឹកអណ្ដូងក្បែរជាអាទិ៍ អ្នកផងសន្សំជងក្រស្រ័យបាន ។

៤២ — សាស្នាសោកណាមានត្របប់ ស៊ង្ឃខបុរាសកប្រតិបត្តិ តិច មិនឃើញអ្នកណាបានសម្រេច វិទ្យាខ្ពស់ជាប់ដល់សំរេច ។ បើល្អមិនឃើញរតន៍បុគ្គល គេសង្ស័យខ្លួនដល់ដើមដាន ដប់មោឃព្រឹទ្ធ គ្នាហាន ព្រល្បីដែលបានបំផ្លាញលោក ។

ឥត្ថីវគ្គ

៤៣ — នារីរូបល្អោភក្រក់ក្រែ មារយាទថ្លៃវាំងចិត្តក៏សោភា វិសេសជាងស្រីល្អរូបា ចិត្តលោភាមិនល្អមិនកាមរាគ ។

៤៤ — តរុណីស្អាតរូបសប្បាយភ្នែក កុមារីប្លែកចិត្តសល្អ សប្បាយ
ចិន្តាក្តីបវរ ក្នុងលោកកម្រនឹងបានជួប ។

៤៥ — ប្រុសស្រឡាញ់នារីច្រើនមិនបានការ ចំណីអាហារ
ច្រើនមុខលំបាកល្អក ចិត្តសង្ស័យខ្នៃមិនងាក់គ្មានប្រែក រកលល្អកមិន
ចុះជ្រុះសោះទទេ ។

៤៦ — ប្រុសរើសភរិយា រូបឆ្នាក្តីប្រា ចិន្តាមិនត្រូវ មួយសល្អដែរ
ទាស់តែល្អង់ខ្មៅ ចង់ដើរច្រើនផ្លូវ ជួបភ្នែកស្រលៀង ។

មនុស្សរើសចំណី ក្តោប្រាមិនធំ រើសអើងបែរបៀង រកជ្រូកមាន់
ទា សម្រាប់ជប់លៀង ដល់ឃ្លានមិនទៀង ល្អកពាងត្រហុក ។

៤៧ — ពោលច្រើនស្របស្រី ខុសច្រើនស្រដី អ្នកខំធ្វើការ
គិតច្រើនអាពាធ ប្រាជ្ញចាញ់ពាលា កូនច្រើនមេបា ប្រាជ្ញាសោកំណ ។

៤៨ — ស្រីស៊ីរល័យយកប្តីចិត្តឯង ស្រីបុកណាតែងតាមម៉ែឪ
គោជិតក្តីស្រែគង់ស៊ីស្រូវ នារីរើសផ្លូវក្ពាត់កិរិយា ។

៤៩ — ប្រុសស្ទាប់ផ្កាប់មុខស្រឡាញ់ស្រី ទារពេជ្រមាសចុំ
ខ្សែទំហុំ សំពត់ភាវហូលព្រែតំនូរ គិតគូររកឲ្យតាមពេញចិត្ត ។

៥០ — លំអងក្រអូបការពារផ្កា លំអងកញ្ញាការពារស្រី ក្នុង
ការនះយាបាយគ្លួកនារី សុំបការចុំ ។ សឹងបានផល ។

៥១ – បច្ចុប្បន្នសព្វថ្ងៃ នារីសម័យ មានសមភាព ស្មើនឹងបុរស មិនមែនបោកខោប ប្រុសខ្លះចាញ់កប ប្រៀបផ្ទឹមពុំបាន ។ នាងរៀនអក្សរ ហត្ថកម្មបវរ ក៏ចេះចំណាន រៀនបើករថយន្ត ឬអា-កាសយាន ស្ត្រីធ្វើទាហាន រសយកខ្លួនប្រុស ។

៥២ – កញ្ញាសោឡសដូចគំនូរ លាបពណ៌គិតគូរសោមសិបគត់ ផលក់លំខពិតដោយសន្ទត សែសិបឆ្នាំកត់តាមមាត្រា ។

៥៣ – នារីមាយាស្មៀមមិនស្តី បើខ្ទនបតីព្រងើយប្រាណ ញ័រខ្វះគតពោលពាក្យកល្យាណ ពិនិត្យតាមអានឲ្យដឹងច្បាស់ ។

៥៤ – ពេលទ្រព្យបុណ្យស័ក្តិខឹងស្ត្រី ប្រែខុសប្រក្រតីដូចសុរិយា មិនដែលនៅទៀងទិសបូព៌ា នេះជាធម្មតាគាត់តែងឡើង ។

៥៥ – នារីស៊ីវិល័យក៏ស្រស់ស្អាត ប្រព្រឹត្តខុសបាវបទបវេណី ប្រុសស្រីដើរលេងដូចអគ្គី កាំប្រៀងធំកស៊ីឆេះដល់ចិត្ត ។

៥៦ – ស្នេហ៍តាមបចមសប្បាយប៉ុក ដល់ក្រោយដេកស្រែកយំទុក្ខសោក ជាតិអាហារល្វីងបាយប្រកដោក ឆ្ងាញ់តាមបយោគក្រោយហើមពោះ ។

៥៧ – សម័យគុឡូរនារីថ្ងៃ ដោយស៊ីវិល័យតែងប្រាណស្រស់ ស៊ុតសក់ឆ្ពោញសសាច់លាបប្រេស ម្ចាំងមន្ទិលអស់ប្រុសព្រិលភ្នែក ។

(៣០៣)

ប្រជុំពាក្យចាស់ផ្សេងៗ

លោកប៉ាយ-ប៊ុក ប្រែរៀបរៀង

(តទៅ)

---

36 - Ni regret du passé, ni peur de l'avenir -

៣៦ - កុំស្ដាយអតីត, កុំខ្លាចអនាគត -

"បើធ្វើអ្វីខុស ព្យាយាមកំលុះ ឧបសគ្គគ្រប់យ៉ាង កែខ្លួនជាថ្មី កុំបីបៀសកង ចំគិតកសាង ជាតិសាស្ដ្រគ្នា" ។

37 — Noblesse oblige

៣៧ - សភាពអភិជន នាំឲ្យប្រព្រឹត្តធម៌ថ្លៃថ្លា -

"ត្រកូលខ្ពង់ខ្ពស់ យល់ហេតុផលស្មោះ ហិរិឧត្តប្បៈ ប្រព្រឹត្ត សោភ័ណ ទើបបានថ្លៃថ្លា គេលើកទុកជា អភិជនពិត" ។

38 — Hors l'honneur nul souci —

៣៨ - ខំគ្មានបារម្ភអ្វី ក្រៅពីកិត្តិយស -

"ត្រូវរក្សាកិត្តិយសតាមឋានា ការពារកុំឲ្យមានសៅហ្មង ដូចបុត្រ ប្រិមប្រិយនៃខ្លួនហោង គួរបង់ចិត្តចាំកុំប្រហែស" ។

39 — Tiens quoiqu'advienne—

៣៩ - ត្រូវប្រឹងខ្លួនជាមុន ក្នុងការដែលមានគ្រោះថ្នាក់ -

"គ្រោះថ្នាក់មកដល់ ត្រូវរងតាមកល ញញឹមកក្រៅ ធ្វើចិត្តឲ្យមុត តយុទ្ធបប្ផា-មិត្តមកព្រះគារ កុំឲ្យរន្ធត់" ។

40 - Plus deuil que joie -

៤០ - មានសេចក្ដីទុក្ខសោកច្រើនជាងរីករាយសប្បាយ -

"ក្នុងនាលោកិយ ទាំងប្រុសទាំងស្រី ត្រូវខំប្រឹងប្រែង ស្វែងរកក្តីសុខ ដែដើងខ្ទាត់ខ្ទង ទ្ទល់ខ្ទាយចាត់ចែង កិច្ចការសារពើ ។ ទើបបានកេរ្តិឈ្មោះ នាមល្បីពីរោះ សាយសព្ទអន្ទើ ដោយទុក្ខព្រួយសព្ទ ដួយជាតិស្មោះស្មើ បានច្ចើងត្រាន់បើ ទុក្ខទោសអនេក" ។

41 — Qui n'a confience n'a rien—

៤១ — ប៉ើគ្មានទុកចិត្ត ក៏គ្មានបានការអ្វីទ្បើយ —

"កិច្ចការរាក់ជ្រៅ ដែលយើងដម្រូវ ឲ្យធ្វើដូចម្តេច លុះតែយើងជឿ ទុកចិត្តជាស្រេច ទើបបានសម្រេច ដូចយើងបំណង" ។

B) - DIVERSES DEVISES

ផ្នែកបាវចនាផ្សេងៗ

1 - Liberté, Egalité, Fraternité —
Devise de la république française

១ — សេរីភាព, សមភាព, ភាតរភាព

បាវចនាសាធារណរដ្ឋបារាំងសែស ។

2— Dieu protège la France —
Devise de la monarchie française

៦ — ព្រះម្ចាស់ស្លត់ ទ្រង់ការពារប្រទេសបារាំង-

បាវចនា រាជាធិបតេយ្យបារាំង ។

3— Honni soit qui mal y pense —
Devise des chevaliers de la Jarretière

៣ — អ្នកដែលគិតអាក្រក់ ត្រូវធ្វើឲ្យខ្មាសកណ្តាលជំនុំជន-

បាវចនា របស់ពួកជិះពាដី សារីចែរ ។

4 — Je maintiendrai —
Devise de la maison de Nassau

៤ — ខ្ញុំនឹងជានាឲ្យនៅដូចដើមតទៅ

បាវចនា នៃរាជវង្សណាស្សូ ប្រទេសហុល្លង់ ។

5 — Droit et vérité —
Devise de l'ancien Royaume de Suède et de Norvège

៥ — សិទ្ធិ នឹង សច្ចៈ

បាវចនា រាជាធិបតេយ្យនៃរាជអាណាចក្របុរាណ ប្រទេស-

ស៊ុយអែត នឹងណរវែស ។

6 — L'union fait la force —
Devise de la Belgique

៦ — សាមគ្គី កើត កំឡាំង

បាវចនា ប្រទេសបេលស៊ិក ។

7 — Dieu et mon droit
Devise de la maison Royale d'Angleterre

៧ — ព្រះម្ចាស់នឹងសិទ្ធិរបស់ខ្ញុំ

បាវចនា រាជាធិបតេយ្យប្រទេសអង់គ្លេស ។

8 — Par le glaive et par la charrue
Devise du Maréchal Bugeaud

៨ — ប្រើដាវ ផង ប្រើនង្គ័ល

បាវចនា ឧត្តមសេនីយ ប៊ុយស៊ូដ ។

9 — Plus ultra (Encore plus loin)
Devise de Charles Quint

៩ — ឲ្យឆ្ងាយទៅទៀត—

បាវចនា មហារាជ សាល-កាំង-

10 Le méchant ne voit que l'épine
Devise de Mme Tallien

១០— ជនទុបកាច មើលឃើញតែបន្លា

ឧាវចនា អ្នកស្រីតាលីយាង ។

11 — Gradatius (Pas à pas)
Devise de Descartes

១១— សន្សឹមៗ កុំបំបោល-

ឧាវចនា អ្នកជ្រាជ្ញដេស្ការត ។

12 — Quo non asecendam (où ne monterai-je pas)?
Devise du surintendant Fouquet

១២— ម្តេចក៏ខ្ញុំមិនទ្បើងតទៅទៀត-

ឧាវចនា រដ្ឋមន្ត្រីហ៉ីរញ្ញាវត្ថុ ហ្វូកេត៍ ។

13 — Nec pluribus impar (Je suffirais à plusieurs) (emblême un soleil)-
Devise de Louis XIV

១៣— ខ្ញុំមានប្រយោជន៍ សម្រាប់ជនច្រើន (មានរូបព្រះអាទិត្យ
ដាបដ៏មា)

ឧាវចនា - ស្តេចល្វីទី ១៤ ។

14 Beau, dru et court-
Devise de la famille de Beaudricourt

១៤— ល្អ, ខ្ចាំង, ខ្ចី—

ឧាវចនា នៃរាជវង្សបូឌ្រីគូរត៍

15 -- A tout venant beau jeu-
Devise de la Famille de Beaujeu

១៥— អ្នកណាក៏ដោយ ត្រូវទទួលរាក់ទាក់ទាំងអស់

ឧាវចនា របស់រាជវង្សបូហ្ស៊ ។ (នៅមានត)

4 — Je maintiendrai —
Devise de la maison de Nassau

៤ – ខ្ញុំនឹងតាំងឲ្យនៅដូចដើមតទៅ

បាវចនា នៃរាជវង្សណាសូ ប្រទេសហុល្លង់ ។

5 – Droit et vérité —
Devise de l'ancien Royaume de Suède et de Norvège

៥ – សិទ្ធិ នឹង សច្ចៈ

បាវចនា រាជាធិបតេយ្យនៃរាជអាណាចក្របុរាណ ប្រទេស-ស៊ុយអែត នឹងណរវែស ។

6 – L'union fait la force —
Devise de la Belgique

៦ – សាមគ្គី កើត កំឡាំង

បាវចនា ប្រទេសបេលហ្ស៊ិក ។

7 — Dieu et mon droit
Devise de la maison Royale d'Angleterre

៧ – ព្រះម្ចាស់នឹងសិទ្ធិរបស់ខ្ញុំ

បាវចនា រាជាធិបតេយ្យប្រទេសអង់គ្លេស ។

8 – Par le glaive et par la charrue
Devise du Maréchal Bugeaud

៨ – ប្រើដាវ ប្ដុំ ប្រើនង្គ័ល

បាវចនា ឧត្តមសេនិយ ប៊ុយស្យូដ៍ ។

9 – Plus ultra (Encore plus loin)
Devise de Charles Quint.

៩ – ឲ្យឆ្ងាយទៅទៀត –

បាវចនា មហារាជ សាល - កាំង-

10 Le méchant ne voit que l'épine
Devise de Mme Tallien

១០— ជនខូចកាច មើលឃើញវតបន្ទា

ចាវចនា អ្នកស្រីតាលីយាង ។

11 — Gradatius (Pas à pas)
Devise de Descartes

១១— សន្សិមៗ កុំបំបោល-

ចាវចនា អ្នកបោជ្ជដស្ពាត ។

12 — Quo non asecendam (où ne monterai-je pas)?
Devise du surintendant Fouquet

១២— ម្តេចកឹខ្ញុំមិនឡើងតទៅទៀត-

ចាវចនា រដ្ឋមន្ត្រីហ៉ីរញ្ញាវត្ថុ ហ្ទូកេត៍ ។

13 — Nec pluribus impar (Je suffirais à plusieurs) (emblême un soleil)-
Devise de Louis XIV

១៣— ខ្ញុំមានប្រយោជន៍ សម្រាប់ជនច្រើន (មានរូបព្រះអាទិត្ស ដាបដំមា)

ចាវចនា - ស្តេចល្វីទី ១៤ ។

14 Beau, dru et court-
Devise de la famille de Beaudricourt

១៤— ល្អ, ខ្ជាំង, ខ្ជី—

ចាវចនា នៃរាជវង្សបូឌ្ធីគ្លរត៍

15 — A tout venant beau jeu-
Devise de la Famille de Beaujeu

១៥— អ្នកណាក៏ដោយ ត្រូវទទួលរាក់ទាក់ទាំងអស់

ចាវចនា របស់រាជវង្សបូហ្ស៉ ។ (ដោមានន)

ពាក្យផ្តើម

ក្នុងទស្សនាវដ្តីខែមុននេះ យើងបានចុះផ្សាយពាក្យប្រៃនឹងពាក្យ-អធិប្បាយ ដែលយើងបានដកស្រង់យកមកអំពីច្បាប់រដ្ឋធម្មនុញ្ញ ប្រ-ទេសកម្ពុជា ។ ក្នុងទស្សនាវដ្តីខែនេះ ទីធ្លាខែផ្តាំជាប់តទៅ យើងនឹងចុះផ្សាយពាក្យប្រៃផ្សេង ។ របស់គណកម្មការវិបស្សនាធម៌ តាំងពីពេលចាប់ផ្តើមធ្វើទ្វេរ៉ាងជាដំបូង គឺតាំងពីថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៤៦ ម៉ោង ១៨ នឹង ៣០ នាទី ក្រោមអធិបតីព្រះសង្ឆអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-យុត្តិវង្ស ជំនុំទៅធ្លុះលោកហ៊ីម-ចំរ៉ែន ធ្វើជុកទ័ពហាន់ ភ្នំពេញ ។

ពេលខាងដើមឆ្នាំ ១៩៤៧ គណកម្មការវិបស្សនាធម៌លើកទៅជំនុំប្រៃ ពាក្យផ្សេង ។ ទៅបន្ទូលលេខានុការរដ្ឋសភា ក្រោមអធិបតីអ្នកអង្គម្ចាស់ វ៉ាន្ទាយ៉ាវង្ស រដ្ឋមន្ត្រីយុត្តិធម៌ ។

ក្រោយមកក្នុងដើមឆ្នាំ ១៩៤៨ ទើបពាងការចាត់តាំងគណកម្មការវិប្ស-ធម៌ជាផ្លូវការ ចាប់ជំនុំដំបូងនៅមន្ទីរក្រសួងសិក្សាធិការ ក្រោមអធិបតី លោកឈាន-រ៉ែ រដ្ឋមន្ត្រីសិក្សាធិការ ។ ដោយហេតុក្រសួងសិក្សាធ-ការតាំងនៅទីប្រជុំផ្លូវធំ ជាទីអ៊ូអរពេក មិនស្រួលដល់កិច្ចជំនុំរបស់ គណកម្មការដែលត្រូវការទីស្ងាត់ ទើបគណកម្មការលើកទៅជំនុំនៅ ទីចាត់ការ សាលាចាស់ជាន់ខ្ពស់ ក្រោមអធិបតី ព្រះមហាសុមេធា-ធិបតី សង្ឆនាយកគណៈមហានិកាយ ដកចេញមកដល់សព្វថ្ងៃនេះ ។

តាំងពីពេលដែលរាជការចាត់តាំងគណកម្មការជាធ្វូរការឡើង គណ-
កម្មការត្រូវជំនុំគ្នាក្នុង ១ អាទិត្យ ២ ដង គឺថ្ងៃអង្គារ និងថ្ងៃសុក្រ ពីម៉ោង
១៨ ទៅម៉ោង ២០ ។

ពាក្យថ្មីទាំងឡាយ ដែលយើងនាំយកមកចុះផ្សាយក្នុងទស្សនាវដ្តីនេះ មានតែពាក្យចុារាំងនឹងពាក្យប្រជាភាសាខ្មែរ គ្មានពាក្យអធិប្បាយ ប្រកបផងទេ តាំងពីដំបូងមក ។ ការចុះផ្សាយពាក្យថ្មីៗនេះ ជានយោ-ចុាយមួយ ដែលជួយពង្រីកភាសាខ្មែរ ឲ្យកាន់តែស្តុកស្តម្ភចំរើនឡើងក្នុងឃ្លាំងនៃអក្សរសាស្ត្រខ្មែរបច្ចុប្បន្នេះ ។

ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថេម

សព្ទចាកំដប្រែជាខ្មែរ

របស់គណកម្មការរបឯធម៌ បានប្រែគ្រោមអធិបតី

នៃព្រះសពអ្នកអង្គម្ចាស់ ស៊ីសុវត្ថិយុត្តិវង្ស

Loi = បញ្ញត្តិ (ព្រះរាជបញ្ញត្តិ)

Loi organique = បញ្ញត្តិរបៀប

Décret = ក្រិត្ស, ព្រះរាជក្រិត្ស

Arrêté = អនុក្រិត្ស, ព្រះរាជានុក្រិត្ស

Décision = សម្រេច (សម្រាប់រដ្ឋមន្ត្រី)

— id — = ដីកា (សម្រាប់ចៅហ្វាយទេត្ត)

Règlement = បទបញ្ជា

— id intérieur = បទបញ្ជាក្នុងក្រសួង

Droit = ច្បាប់

Droit (faculté) = សិទ្ធិ

Droit civil = ច្បាប់រដ្ឋប្បវេណី

Droit public = ច្បាប់មហាជន

Droit privé = ច្បាប់ឯកជន

Droit civique = ច្បាប់ពលរដ្ឋ

Droit pénal = ច្បាប់ព្រហ្មទ័ណ្ឌ

Droit international = ច្បាប់រវាងប្រទេស

Droit international privé = ច្បាប់ឯកជនរវាងប្រទេស

Droit international public= ច្បាប់មហាជនរវាងប្រទេស

Voter = បញ្ចេញមតិ

Discuter = ពិភាក្សា, ជជែកគ្នា.

Promulguer = ប្រកាសឲ្យប្រើ

Sanctionner = ឲ្យអនុមតិ

Ratifier = ឲ្យសច្ចាបំនួ

Initiative = ដើមគំនិត

Projet de loi = សេចក្តីព្រាងបញ្ញត្តិ

Proposition de loi = សេចក្តីស្នើបញ្ញត្តិ

Code = ក្រម

Article = មាត្រា, ប្រការ.

Législature = នីតិកាល

Session = សម័យប្រជុំ

Séance = ពេលប្រជុំ

Bureau = ក្រុមអភិបាល (សំព្ធរដ្ឋសភា)

Bureau définitif = ក្រុមអគិបាលស៊ប់ - ពេញទី

Président = ប្រធាន, អធិបតី

Vice président = អនុប្រធាន, អធិបតីរង

Secrétaire = លេខាធិការ

Secrétaire Général = អគ្គលេខាធិការ

Attribution = មុខការ

Condition d'éligibilité = លក្ខណសម្បត្តិនៃបេក្ខជន

Loi en vigueur = ធរមានបញ្ញត្តិ

Finances = ហិរញ្ញវត្ថុ

Budget = ថវិកា (ការគ្រោងប្រាក់ចំណាយចំណូល)

Question sociale = បញ្ហាស៊ង្គម

Question culturelle = បញ្ហាវប្បធម៌

Pétition = ពាក្យប្តឹងសុំ

Exposé des motifs = សេចក្តីថ្វែងហេតុ

Cause = បុព្វហេតុ

Avis = យោបល់, ប្រកាស

Vœu = បំណង

Disposition spéciales = របៀបពិសេស

Interpellation = សំនួរដេញដោល

Famille = ត្រួសារ ត្រកូល, អំបូរ

Tribu = ឆុលសម្ព័ន្ធ

Clan = បក្ខសម្ព័ន្ធ

Peuplade = រ៉ប្រជាគម

Société = សង្ឥម

Association = សមាគម

Patriarcat = បេតេយ្យកា

Matriarcat = មត្តេយ្យកា

Nation = ប្រជាជាតិ

National = នៃប្រជាជាតិ, របស់ប្រជាជាតិ

Etat = រដ្ឋ

Peuple = ប្រជាពស្ត្រ, ប្រជានុពស្ត្រ

Population = ប្រជាជន

Habitant = អ្នកស្រុក

Sujet = អនុពស្ត្រ, អនុជន

Titre = ចំពូក

Partie = ភាគ, ចំណែក (មាតត)

(4)

ប្រវត្តិសាស្ត្រសង្ខេបឥណ្ឌា

ហ្លួងធិពត្ថុមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

វគ្គទី ៣

ព្រះបាទមិលិន្ទ្រ-វង្សយួអេជី លទ្ធិមហាយាន

មានដែនដីមួយក្នុងសម័យបុរាណហៅថា បាកត្រៀន ហើយក្នុងវេលានេះហៅថា ទួរគីស្ថាន នោះលក្ខណៈរបស់ក្រុមប្រទេសក្នុងសម័យគ្រានោះ មានទំនងដូចគ្នានឹងអាហ្វកានីស្ថានក្នុងសម័យនេះ គឺថាជាស្រុកសំខាន់តាមផ្លូវយុទ្ធសាស្ត្រនិងផ្លូវជំនួញ ជាទីសម្រាប់ក្ដាប់គ្នារវាងដែនអ៊ីរ៉ាននឹងឥណ្ឌា ហើយមានផ្លូវឡើងអំពីឥណ្ឌាទៅស្រុកចិនផង ទាំងទីដីក៏មានដីជាតិល្អច្រើន ៗ ទៀតដែនបាកត្រៀននេះ គួររាប់ថាជាដែនដីរបស់ពួកអរិយកៈសុទ្ធ ព្រោះពួកដែលលុកចូលមកក្នុងឥណ្ឌាក្ដី ឬដែលលើកចូលទៅក្នុងប្រទេសពែរ្ស៍ ហើយក្លាយទៅជាពួកម៉ែតដូចពោលរួចមកហើយក្ដី សុទ្ធតែជាពួកបាកត្រៀននេះឯង ៗ ជនបំពួកនេះបានថែរក្សាសភាពដើមពិតប្រាកដរបស់ខ្លួនទុកបាន មិនបាច់លាយច្របល់ផ្សំនឹងជាតិដទៃទេ កាលព្រះបាទអាលេក្សង់ដ្រឹចូលលុកលុយដល់ដែនដីនេះ ក៏ទ្រង់យល់ភ្លាមថាជាទីតំបន់ដ៏សំខាន់មួយ ទើបទ្រង់យកខែត្របាកត្រៀននេះ ជាទីរួមប្រជុំស្រុកចំណុះផ្សេង ៗ របស់ព្រះអង្គ

និងស្រុកចំណុះឯទៀត ៗ នៅតំបន់អស់នោះ ដែលព្រះបាទអាលេក្សង់ឌ្រ ទ្រង់តាំងមេទ័ពឲ្យកាន់កាប់រក្សាជាដំណាងព្រះអង្គ គឺខេត្រសុកដៀន, អារៀ, ម៉ាយៀន, ដ្រាងយៀន, អារាកូស៊ីនិងគន្ធារៈ ក៏ជាចំណុះរបស់ស្រុកបាក់ទ្រៀនទាំងអស់ ហេតុដូច្នេះ អាណាខេត្របាក់ទ្រៀននេះ ទើបក្លាយទៅជាអាណាចក្រក្រិកស្វ័យភាព ។

បណ្ដាស្រុកចំណុះអស់នេះ ព្រះបាទអាលេក្សង់ឌ្រទ្រង់តាំងទាហានរក្សាទុកជាចំនួនច្រើន នៅតំបន់ខ្លះ មានពួកទាហានជាតិអ៊ីរ៉ង់និងជាតិក្រិកជាចំនួនរាប់ហ្មឺនក៏មាន ។ កាលអស់បុណ្យព្រះបាទអាលេក្សង់ឌ្រទៅ ពួកមេទ័ពតាងព្រះនេត្រព្រះកាណ៌អស់នោះ ក៏មានចិត្តរំលោភឡើង រៀងខ្លួនតាំងខ្លួនជាឯករាជ្យឡើង ។ គ្រានោះ មានមន្ត្រីស្ដេចអាលេ-ក្សង់ឌ្រម្នាក់ឈ្មោះឌីយោដុត ដែលជាអ្នកគ្រប់គ្រងខេត្របាក់ទ្រៀន បានប្រកាសតាំងខ្លួនឡើងជាក្សត្រគ្រងរាជសម្បត្តិ កាលពុទ្ធសករាជ ២៩៣ ទ្រង់ព្រះនាមព្រះបាទឌីអូដុតទី ១ ហើយព្រះមហាក្សត្រអង្គនេះ បានសំដែងសេចក្ដីក្លៀវក្លាអង់អាចក្នុងលុកលុយរហូតដល់ខែត្រប៉ារត៏ តែជួនជាគ្រោះមិនល្អ ទ្រង់ទិវង្គតទៅមុននឹងការបានសម្រេចរៀបរយ ។ ព្រះរាជ-ឱរសរបស់ព្រះអង្គ ទ្រង់ព្រះនាមឌីអូដុតទី ២ បានទទួលគ្រងរាជ្យជាដំណតមក តែត្រូវពួកមន្ត្រីក្រិកប្រចាំខេត្រសុកដៀនឈ្មោះ យូធីដឹម លុបលាងអំណាចអស់ទៅកាលពុទ្ធសករាជ ៣១៨ ហើយតាំងខ្លួនជាក្សត្រ

គ្រងរាជ្យនៅសុកនៅ, ឡាកគ្រ, ម៉ារយ៉ានទីងអារៀរហូតដល់ឆ្នាំ
ពុទ្ធសករាជ ៣៤៣ ។ ព្រះបាទយុធិដ្ឋិរមានតែនៅជាមហាក្សត្រ
ដែលមានវិជ្ជាអំណាចយ៉ាងធំវ៉ៃក្រលែងមួយក្នុងប្រទេសតណ្ឌ តែជួនជា
មានមហាក្សត្រប្រទេសស៊ីរ៉ៃ ព្រះនាមអន្ធិអូគុសទី ៣ បានធ្វើចម្បាំង
លុកលុយបានជ័យជំនះពួកប៉ារធ៍ ហើយទ្រង់លុកចូលតមកទៀតក្នុង
ដែនឡាកគ្រ ។ ដំបូង ព្រះបាទយុធិដ្ឋិរទ្រង់ព្យាយាមតស៊ូទប់ទល់
យ៉ាងមុះមាត់ តែជាលទ្ធផលក្រោយគ្រាងទ្ធូលចុះចាញ់ ហើយបណ្តា
ការណាវ៉ៃត្រូវបានរ ព្រះបាទយុធិដ្ឋិរ ក៏ធ្លាក់ទៅនៅក្រោមអំណាចរបស់
ព្រះបាទអន្ធិមអូគុសជាប្រចាំ ឯព្រះបាទយុធិដ្ឋិរនៅតែជ្រើសរើ ព្រះពាជ-
អំណាចត្រួតត្រាបានត្រឹមដែនឡាកគ្រនៃងសុកនៅប៉ុណ្ណោះ ។ ការ
ព្រះបាទយុធិដ្ឋិរក្សាយ ព្រះជន្មហើយ ព្រះពាជ្ញារបស់ទ្រង់ ១ ព្រះនាម
ឌីមីត្រីអូសបានទ្ធូលគ្រងរាជសម្បត្តិតមក ហើយគ្រប់គ្រងដែនដីចាងពីរ
ចំណែកនេះ ក្នុងរវាងឆ. ស. ៣៤៣ ដល់ ឆ. ស. ៣៥០ ទ្រង់មាន
អំណាចខ្លាំងក្លាឡើងជាងដើម ដោយចម្បាំងលុកលុយបានដែនបញ្ជាប
ក្យបានស្រុកសង្ហ្ម:ហើយចុះមកទាងតួងក្យបានស្រុកប៉ាកតា លេខ
ក្នុងសម័យនេះហៅថា សិន្ធនីងដែនសុកស្ត ។

ប៉ុន្តែការធ្ងាយអំណាចរបស់ព្រះបាទឌីមីត្រីអូសនេះ ត្រូវការតាមដាប
ចេញក្នុងការកត់ត្រាការ ដោយមានមេទ័ពម្នាក់របស់ទ្រង់ក្ស្ត

ទ្រង់ គ្រាតែទ្រង់ត្រូវបាត់ដែនឫកត្រូនទ្រង់សកដៀន ហើយនៅ
ដែនឯទៀតៗ ដូចការរៀទ្រង់គន្ធារៈក៏តាំងជានគរតូចៗឡើង មានជនជាតិ
ក្រិកជាច្រើនហ្វាយត្រួតគ្រានគរ ។ លុះតមកដល់ពុទ្ធសករាជ ៣៦៣
ព្រះបាទយុគ្រាតិជាស ទើបត្រូវប្រជុំប្រមូលកស្ត្រីអស់នោះមកទុកក្នុង
អំណាចរបស់ព្រះអង្គបានវិញ ទើបគួរជាប់ចា ទ្រង់ជាមហាក្សត្រ ១
អង្គរបស់ជាតិក្រិកក្នុងតណ្ហ្ហ តែទ្រង់មិនបានជាយកព្រះទ័យទុកជាក់
ទ្រង់ដែនដ៏ធំធូលាយរបស់ក្រិកនៅទាងធ្លើងនុ៎ះឡើយ ទើបជាហេតុឲ្យជន
១ ពួកដែលមានឈ្មោះចា យ្ហូអេដ៏ មានកូមិលំនៅក្នុងតំបន់អស់នោះ
ប្រជុំកម្ចាំងតាំងជាកងទ័ពឡើង ហើយបានទៅវាយជណ្តើមយកខ្មែ
សកដៀនទៅបាន អំពីព្រះបាទយុគ្រាតិជាស តែទ្រង់ទៅមានកំឡាំង
ទប់ទល់ការពារដែនឫកត្រូនទុកបាន តែទ្រង់មិនទាន់អស់ត្រោះតមក
ព្រះអង្គត្រូវ ព្រះពាជទ្រាស ១ អង្គរបស់ទ្រង់ធ្លើតត់ទៅ កាលពុទ្ធសករាជ
៣៧៤ ។ កាលអស់បុណ្ណ្យ ព្រះបាទយុគ្រាតិជាសហើយ អាណាចក្ក
របស់ក្រិកក្នុងតណ្ហ្ហ ក៏ចែកខ្ចែកចេញជាភាគ ។ អស់ទៅ ។ ១ភាគជាក
ទៅជារបស់ អាប៉ូលណៅដូត ដែលជា ព្រះពាជទ្រាសឫស្ស ១ របស់ ព្រះ
បាទយុគ្រាតិជាស ។ ចំណែកទាងគន្ធារៈ, ប្ដូរ:ប្ដូរ: ទ្ធ ស្ត្រ
ត្ត ក្ត ស ល ។ នោះរួមគ្នាជាអាណាចក្ក ១ ទៀត មានក្សត្រគ្រប់គ្រងតមក ។
ក្នុងពុទ្ធសករាជ ៣៩២ មហាក្សត្រដែលគ្រងអាណាចក្រនេះ ជាពួជ

ត្រកូលជាតិក្រិក ព្រះនាម មេនន្ទ័រ តាមគម្ពីរព្រះពុទ្ធសាសនាហៅថា ព្រះបាទមិលិន្ទ ទ្រង់មានរឿងអំណាចលុបលាងអំណាចក្សត្រ ដែលទទួលគ្រងរាជសម្បត្តិតមករបស់ព្រះបាទយុក្រាតិដាស ពេញបានសម្រេច ហើយទ្រង់ទៅជាមហាក្សត្រដ៏មានវិជ្ជានុភាពឡើងក្នុងតំបន់នោះ ទ្រង់បានតាំងទីក្រុងនៅស្រុកសគ្គលៈ ទ្រង់បានវាតការត្រួតត្រាយ៉ាងរឹងប៉ឹង ទ្រង់បានពង្រីកអាណាខេត្ត មកខាងទន្លេគង្គា បើគិតប្រៀបធៀបពីព្រះរាជអំណាច ក្រៅពីព្រះបាទអាលេក្សង់ដ្រ៍មហារាជហើយ មិនមានក្សត្រជាតិក្រិកអង្គណាផ្ទឹមបានស្មើនឹងព្រះអង្គឡើយ ។

តមក ទើបពួកយូអេជិលុកលុយចូលមកក្នុងអាណាខេត្តរបស់ព្រះអង្គ ព្រះបាទមិលិន្ទ ទ្រង់នាំទាហានថយមកកណ្តាលដែនដីនៃប្រទេសឥណ្ឌាបន្តិចម្តង ៗ ដរាបដល់បានស្រុកមធុរៈ ដែលតាំងនៅតាមមាត់ទន្លេយមុនា ហើយហួសចូលមកក្នុងដែនកោសល ទ្រង់យកបានស្រុកសាកេតនិងអយោធ្យា ហើយលុកយកក្រុងរាជគ្រឹះ (ដែលបានផ្លាស់ឈ្មោះថា វិហារ កាលរាជ្យព្រះបាទអសោក) ហើយទ្រង់លុកហួសចូលទៅដល់ស្រុកបាដលីបុត្រ ដែលសព្វថ្ងៃនេះហៅថា បាតនា រួមសេចក្តីថា ព្រះបាទមិលិន្ទទ្រង់រាយលុកយកឥណ្ឌាបានដែនដីច្រើន ជាងព្រះបាទអាលេក្សង់ដ្រ៍មហារាជទៅទៀត ហើយទ្រង់បាននាំយកអារ្យធម៌របស់ក្រិកមកផ្សំលាយគ្នានឹងព្រះពុទ្ធសាសនា ។

តាមដោយពិត ក្នុងឆានដំបូង ព្រះបាទមិលិន្ទ្ធ ទ្រង់ខ្ជាប់ខ្ជួនទាំងសាសនារបស់ក្រិក ដែលមានចំនួនព្រះរាប់មិនអស់ ដូចបានលោលមកហើយក្នុងពង្សាវតារបស់ក្រិក ។ មួយវិញទៀត ការដែលព្រះបាទមិលិន្ទ្ធលើកទ័ពមកញ៉ាំញីនឹងធ្វើអន្តរាយដល់ស្រុកសំខាន់ផ្សេងៗ ដូចក្នុងរាជត្រីនឹងបានដល់ប្រជាជនមានដើម ទ្រង់មានព្រះបំណងនឹងបំផ្លាញព្រះពុទ្ធ-សាសនាដោយពិត តែចួនជាយប់ ១ នោះ ព្រះចន្ទ្ធកំពុងពេញវង់ក្នុងថ្ងៃពេញបុណ្ណមី ព្រះបាទមិលិន្ទ្ធមានព្រះរាជហឫទ័យចូលថ្នាន់ទ្រង់ប្រ-ស័យសន្ទនានឹងអ្នកចូលជ្ឈណាមួយ ដែលជាកិត្តិក្នុងព្រះពុទ្ធសាសនាបុគ្គលព្រាហ្មណ៍ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាអ្នកចូលជ្ឈ នៅទីបំផុតទ្រង់ចាន់ជួបប្រទះនឹងព្រះនាគសេនត្ថេរ ទើបមានការជជែកគ្នានឹងទ្រង់ប្រ-ស្ទាផ្សេងៗ ដូចមានសេចក្ដីពិស្ដារក្នុងគម្ពីរមិលិន្ទ្ធបញ្ហានោះស្រាប់ ត្ថេ- រាប់ថាជាគ្រាដំបូងក្នុងពង្សាវតារ ដែលអ្នកចូលជ្ឈជាតិក្រិកជាអ្នកមានសំដីថ្លៃ-ម៉ាត់យ៉ាងល្បីល្បាញក្នុងលោក ចានមកល្បងសំដីថ្លៃម៉ាត់នឹងព្រះសាវ-ករបស់ព្រះពុទ្ធជាម្ចាស់ នៅទីបំផុតនៃការសាកចូ ព្រះរាជាជាតិក្រិ-ព្រះអង្គក៏ទ្រង់ចាញ់ព្រះពុទ្ធសាវក ហើយទ្រង់ប្រកាសព្រះអង្គជាពុទ្ធមា-មក: ទ្រង់ទទួលជាសាសនូបត្ថម្ភក៏យ៉ាងម៉ឹងម៉ាត់ ត្ថេ- រាប់ថាជាទីពីរបន្ទាប-អំពីព្រះបាទអសោកមហារាជមក ដោយទ្រង់ចានទ្ទ្ធកបំរុងព្រះពុទ្ធ-សាសនា ឲ្យចានចំរើនរុងរឿងឡើងពិតៗឡើងវិញទៀតក្នុងប្រទេសតណ្ហ-

ទ្រង់បានកសាងវិហារសាលាឡើងជាចំណាត្រៀងដំកើងព្រះកិត្តិយសរបស់ព្រះអង្គជាច្រើន ។

ព្រះបាទមលិន្ទ្រទ្រង់ទិវង្គតទៅក្នុងព្រះពុទ្ធសករាជ ៤១៣ កិច្ចការដែលទ្រង់បានធ្វើ គឺទ្រង់បាននាំយកគំនិតគិតគូររបស់ក្រិកមកផ្សាយគ្នានឹងលទ្ធិពុទ្ធសាសនា ជាហេតុនាំឲ្យព្រះអង្គបានទទួលសេចក្ដីនិយមរាប់អានជាយូរអង្វែងតមក មានក្សត្រព្រះវង្សដែលជាជាតិក្រិកបានទទួលរាជសម្បត្តិតមក អង្គចុងក្រោយបង្អស់ គឺហេរមេអុស ដល់មកក្នុងពុទ្ធ-សករាជ ៥១៣ រាជវង្សរបស់ព្រះបាទមលិន្ទ្រក៏ដាច់ផុត ដោយត្រូវពួកយូអេជី លុកលុយចូលមកគ្រប់គ្រងទៃត្រដែនបាក់ត្រៀន ។

ឯពួកយូអេជីនេះ ជាជាតិទួរគីនឹងម៉ុងកូលីលាយគ្នា ចាប់តាំងអំពីចិនតាំងរាជអាណាចក្របានមាំមួនឡើងកាលពុទ្ធសករាជ ៣២៣ នោះ មានកើតចលាចលវឹកវរក្នុងទ្វីបអាស៊ីភាគកណ្ដាលជាច្រើន ៗ ព្រះរាជា-ធិរាជរបស់ចិនអង្គដំបូងៗ បានពង្រីកអាណាខេត្តដេញពួកជនជាតិសំ-បុរលៀនដែលហៅថា ហាងបុហ័ន ដែលត្រូវជាបុព្វបុរសរបស់ពួកទួរគីម៉ុងកូលីក្នុងសម័យនេះ ទើបធ្វើឲ្យហ័ននឹងចិនទៅជាសត្រូវគ្នាយ៉ាងធំ ដូចមានសេចក្ដីសារសេរក្នុងប្រវត្តិសាស្ត្រចិនរួចមកហើយ ៗ ក្នុងខណៈដែលចិនកំពុងមានអំណាចបណ្ដេញពួកហ័ន ឲ្យបែកខ្ចាត់ខ្ចាយក្នុងទួរគីស្ថាននោះ ពួកហ័នក៏ថយចេញហើយរុកលុកចូលទៅ

ក្នុងដែនដីរបស់ពួក យូអេជី ហើយពួកយូអេជីក៏ត្រូវតែថយចុះទៅខាងក្រោមទៀត ប្អូនជាមាន់គ្រោះល្អ បានធ្វើជាទាយចៅហ្វាយធំឡើងក្នុងប្រទេសគណ្ឋា ។

ពួកយូអេជីនោះមានឈ្មោះច្រើនយ៉ាង តែពាក្យថា យូអេជី ហៅតាមចិន ពួកឥរុបក៏និយមហៅតាមចិនរហូតមកដល់សម័យសព្វថ្ងៃនេះ ។ ឯស្រុកទេសដើមរបស់ជនពួកនេះនៅក្នុងទួរគីស្ថានទិសខាងកើត តែឫសគល់ដើមកំណើតមានមកយ៉ាងណានោះ អ្នកប្រាជ្ញប្រវត្តិសាស្ត្រក្នុងសម័យនេះមិនទាន់ដឹងប្រាកដទេ ឯសំដីភាសាមានទំនងប្រហែលទៅខាងភាសាអារ៉ិយ័ន ។ លុះជនពួកនេះលុកចូលមកដល់ខេត្តដែនសកដៀននិងបាកត្រៀនហើយជនពួកនេះក៏បែងចែកទឹកដីចេញជា ៥ អាណាចក្រនៅត្រួតត្រាជាឯករាជដោយឡែកពីគ្នាមិនបានចំណុះគ្នាទេ ធ្វើដូច្នេះអស់វេលាដល់ ១ សតវត្សរ៍ ។ ដល់អំណើះកាលតមកដល់ពុទ្ធសករាជ ៥១២ មានអាណាចក្រហៅថា កុសាន្ស បានប្រមូលអាណាចក្រទាំង ៤ ទៀតនោះរួមគ្នាជាអាណាចក្រតែមួយបានសម្រេច ។ ឯនាយករបស់ពួកកុសាន្សនេះហៅថាកាតហ្វីសេស បានតាំងខ្លួនឡើងជាស្តេចហើយតាំងវង្សគ្រប់គ្រងអាណាចក្រយូអេជី តមកជាវេលាជាងពីរសតវត្សរ៍ ហើយមានអំណាចរួបរួមបញ្ចូលដែនដីផ្សេងៗ ដែលពួកក្រិកត្រួតត្រាក្នុងគ្រានោះមកជារបស់ព្រះអង្គបាន ។ (នៅមានត)

រឿងសាមគ្គា

អ្នកឧកញ៉ាវិបុលរាជសេនា នូ-កង រៀបរៀង

(តមក)

លីសុកឆ្លើយថា ចូរអ្នកនាំខ្ញុំទៅគំនាប់តេងង្ហួនជាបំគាប់ញ្ញើមអ្នកចុះ លី-ប៉ោក៏បណ្ដេញមនុស្សទាំងអស់ឲ្យដើរចេញហើយឱនខ្សឹបថា អ្នកផឹកស្រាស្រវឹងទេដឹង? ខ្ញុំនឹងអ្នកដឹងស្គាល់មាតាបិតាទាំងសងខាងតាំងពីតូច ហេតុដូចម្ដេចបានជានិយាយដូច្នេះ ដែលយើងមកនៅធ្វើការនឹងតេងង្ហួនហៅជាបិតានោះ ព្រោះចាំចិត្តគិតតែធ្វើខ្លួនឲ្យបានសុខប៉ុណ្ណោះទេ លីសុកថាខ្លួនអ្នកមានឫទ្ធីដែលល្បីឈ្មោះខ្លាំងពូកែក្នុងការសង្គ្រាមជាប្រាកដណាស់ បើនឹងគិតរករបស់អ្វី ក៏គង់សម្រេចសេចក្ដីប្រាថ្នា ហេតុម្ដេចមកចាំចិត្តនៅដូច្នេះ ។ លីប៉ោតបថា ដែលអ្នកនិយាយនោះក៏មែនហើយ តែយើងស្វែងរកទីពឹងដែលជាបង្គោលមាំនោះនៅមិនទាន់បាន ។ លី-សុកញញឹមហើយឆ្លើយថា ធម្មតាសត្វបក្សីតែងពឹងព្រៃព្រឹក្សា ដែលមានផលានុផលទើបបានសេចក្ដីសុខសប្បាយ ប្រវេណីនាហ្មឺនខុំរាជការទាំងឡាយ បើព្រះមហាក្សត្រទ្រង់ទសពិធរាជធម៌ដ៏ប្រពៃ ក៏រមែងបានសេចក្ដីសុខក្រោមម្លប់ព្រះបរមពោធិសម្ភារជាដរាប ដែលអ្នកចាំចិត្តនៅធ្វើការជាមួយនឹងតេងង្ហួននេះ នឹងប្រាថ្នាប្រយោជន៍អ្វី អំណើះទៅឯមុខអ្នកគង់មិនបាន

សេចក្តីសុខនឹងបានទុក្ខកំយអន្ទកយ គួរទ្ទួលទ្ទាយរកនាយចៅហ្វាយជាច្រើនជាជាង ។

លីហ៊ីបានឮដូច្នោះ ក៏សាកសួរលីសុកថាអ្នកធ្វើកដការក្នុងស្រុកក្រុង គង់បានដឹងឮថា នាហ្ជីនណាមានបុណ្យអំណាចអាចតាំងនៅក្នុងផ្ទៃសុចរិតយុត្តិធម៌ ទើងនិយាយការរាជការក៏ស្រែចជាច់ទាតបាន លីសុកធ្វើយថា ខ្ញុំសំឡឹងរកមើលបណ្តានាហ្ជីនមុខមន្ត្រីក្នុងដីក្រុងនោះដែលនឹងឲ្យមានសតិបញ្ញាក្ងាហានបានត្រមនោះ នរណាក៏មិនស្ទើនឹងតាំងតួសោះឡើយ ឯតាំងតួនោះគឺប្រកបនៅដោយសតិបញ្ញាក្ងាហាន មានសន្ធានដ៏សុចរិតពិតត្រង់ តាំងដួងចិត្តក៏ស្ងៀតស្ងត់ទឹងពួកតាហានមានតែឲ្យបំណាច់ផ្ទាន់តាមគុណូបការជាលំដាប់ មិនស្រឡាញ់ទ្រព្យរបស់តែងយកចិត្តមនុស្សជាប្រមាណ អំណើះទៅទាងមុខខ្ញុំឃើញថា តាំងតួគង់នឹងបានជានាហ្ជីនធំបំផុតប្រាកដមិនខាន ។

លីហ៊ីបានស្តាប់ក៏មានចិត្តសោមនស្សត្រេកអរសរសើរថា ខ្ញុំប្រាថ្នានឹងរកទីពឹងយ៉ាងនោះជាយូរមកហើយ តែថារកឱកាសនឹងចេញទៅមិនទាន់បាន ទើបលីសុកស្រាយយកមាសមួយពាន់ដំឡឹង ទឹងតួងពេជ្ជតាំងគ្រាប់ប្រដាប់ខ្សែ ក្រវាត់ក្បាលទ្រមាត់ តាំងអស់មកជាក់ចំពោះមុខ លីហ៊ីឃើញដូច្នោះក៏សួរថារបស់តាំងនេះអ្នកយកមកធ្វើអ្វី? លីសុកធ្វើយថា តាំងតួមានចិត្តស្រឡាញ់អ្នកច្រើនណាស់ ទើបប្រើខ្ញុំឲ្យ

នាំសេះនឹងរបស់ពាំងអស់នេះមកជូន ឯលីហ្ចាជាមនុស្សលោភ លុះឃើញរបស់មានដម្លៃ ក៏មានសេចក្ដីត្រេកអរពន់ប្រមាណ ចានធ្វើយតបថា ដែលតាំងតុ:មានចិត្តស្រឡាញ់ ហើយឲ្យនាំសេះនឹងរបស់មកឲ្យនោះ ខ្ញុំនឹងមានវត្ថុអ្វីទៅតបស្នងសងគុណលោកវិញ ។ លីសុកធ្វើយតបថា អម្បាលដូចខ្ញុំពុំមានថ្លៃដៃអ្វីសោះ ម្តេចតាំងតុមានចិត្តសប្បុរសស្រឡាញ់ សរសើរ ជួយស្នើសេចក្ដីគាប់គុណឲ្យចានធ្វើជានាយទាហានប៉ុណ្ណោះ ចំណាន់បើខ្លួនអ្នកមានចំណេះវិជ្ជាខ្ជាំងពូកែជាងខ្ញុំ បើអ្នកទៅនៅជាពួកក្រុមហើយក៏គង់នឹងឡើងយសសក្ដិជានាហ្ជ៉ិនធំពុំខាន លាកសក្ការៈពាំងអម្បាលម៉ានក៏នឹងមានដល់ខ្លួនអ្នកជាច្រើន ។

លីហ្ចាតបថា ខ្ញុំនឹងយកសេចក្ដីគាប់ឯណាទៅជាជំនួនតាំងតុ ? លី-សុកធ្វើយថា បើអ្នកនឹងយកសេចក្ដីគាប់ទៅជូនចានដោយងាយណាស់ ត្រែងតែអ្នកមិនត្រមធ្វើ បើអ្នកធ្វើហើយក៏គង់នឹងចានក្ងងមួយជំទាស់ម្រាមដៃ លីហ្ចាក៏ស្ងៀមអង្គុយគិតមួយស្រមៃហើយធ្វើយថា ដែលនឹងយកសេចក្ដីគាប់អ្វីៗ ក៏គ្មានសោះ មានតែតេងដ្ឋនជាគូវ៉ាក់ទ្ធគ្នានឹងតាំងតុ ខ្ញុំនឹងកាត់ក្បាលតេងដ្ឋនយកទៅជូនតាំងតុ ហើយសេចក្ដីគាប់ប្រ-សើរគង់នឹងមានដល់អ្នកជាច្រើនណាស់ ឯគំនិតនេះត្រូវគិតយ៉ាងហ៊ាសរួសពន់ តែយូរទៅនឹងលាន់ឮបែកការ លីហ្ចាក៏ទទួលពាក្យប្ដេជ្ញាថាអ្នកចូរវិលទៅដំកបតាំងតុចុះ ត្រីកនេះខ្ញុំនឹងកាត់យកក្បាលតេងដ្ឋន

ទៅជួយតាំងតុជាច្រើនកន្លែង ហើយខ្ញុំនឹងសុំនៅធ្វើពលការជាមួយនឹងតាំងតុ
ឯទៅ ។ លីសុកកីលាលីហ្ចាទៅវិញ យកសេចក្តីនេះទៅប្រាប់តាំងតុ
ត្រាប់ប្រការ លុះដល់ពេលយប់ប្រមាណយាមពីរចុងយ លីហ្ចាក៏យក
ត្រាប៉ីសៀតចង្ក្រានទៅចង្ក្នុ. ហើយដើរចូលទៅដល់ដំណាក់ គេងឆ្លួន
ឃើញគេងឆ្លួនកំពុងតែមើលសំបុត្រ ។

ឯគេងឆ្លួនឃើញលីហ្ចាចូលទៅក៏សួរថា កូនអើយអ្នកចូលមកមាន
ការអ្វី? លីហ្ចាក្រែកគំហ៊ីកថា ខ្ញុំអញ្ជាប្រុសចំពោះមានថ្ងៃដែលស្ងៀ
ល្ងាញ ច្រើនណាស ឯងនឹងមកលើកខ្ញុំនៅតាពុកហៅអញ្ជាកូនគ្មានមិន
សមគួរសោះ គេងឆ្លួនបានឮដូច្នោះក៏ក้ាយណាស់ សួរគ្រាកទ្ធើងនិយាយ
ថា ហេតុអ្វីបានទៅគិតគ្រឲ្យប្រាប់ចិត្តដូច្នេះ លីហ្ចាមិនឆ្លើយតបសោះ ហួត
ត្រាប៉ីសួរចូលទៅកាប់គេងឆ្លួនស្ទាប់ទៅវិញនោះ ហើយកាត់យកក្បាល
ឃ្លីរឡើងក្រែកប្រការសដល់ភាហានតាំងពួងថា គេងឆ្លួនមិនមែនជា
មនុស្សទ្ធៀងត្រង់ទ្ធឹងពាជការផ្ទៃនដ៏សោះ ចំពោះធ្វើការលាមកអាត្រក
ណាស ឥឡូវនេះ យើងសម្ងាប់ចាស់ហើយ អ្នកតាំងឡាយទ្ធឹង
ចង់ទៅធ្វើការជាមួយនឹងយើងប៉ុន្ម្ចានណាក ចុមិនសុំត្រូវនឹងទៅធ្វើការ
ក៏ចូរគិតអានលិទៅស្រុកទ្ធេសនៃខ្ញុំចុះ ភាហានតាំងពួងបានឮឃើញ
ដូច្នោះ នរណាដែលស្ម្ចាប់មិនស្រឡាញ់លីហ្ចា ក៏រត់ចែកចែកទ្ធៅ
ប្រមាណពាក់កណ្តាលត្រ្ចៅពីនោះ នរណាដែលកាប់អានស្រឡាញ់លីហ្ចា

ក៏បបួលគ្នាទៅតាមនៅទីងលីប៉ោប្រមាណពាក់កណ្ដាល លុះដល់ពេលព្រឹកព្រហាម លីប៉ោក៏ឡើងសេះយួរក្បាលតេងង៉ួនចូលទៅរកលីសុកក្នុងបន្ទាយតាំងតុ លីសុកឃើញលីប៉ោ យួរក្បាលតេងង៉ួនចូលទៅដល់ក៏ត្រេកអរណាស់ លេះលាំងនាំខ្លួនលីប៉ោយួរក្បាលតេងង៉ួនចូលទៅគំនាប់តាំងតុក្នុងបន្ទាយ ។

ឯតាំងតុះឃើញលីសុកនាំខ្លួនលីប៉ោទៅដល់ ក៏មានសេចក្ដីត្រេកអរពន់ប្រមាណ បានដើរចេញពីទីលំនៅទៅគំនាប់ទទួលលីប៉ោហើយថា ខ្លួនឃើញឧបមាដូចជាស្រែបានប្រាំងស្ងួតស្រែអស់ហើយ ទទួលភ្លៀងកាំងគោកទឹកអស់ ស្រែស្ងួតណាស់មិនរួចក៏ក្រៀមស្វិតខូចទៅ អ្នកមករកឃើញខ្លួនឡើងនេះដូចស្រែបានទឹកភ្លៀងធ្លាក់មកពេញស្រែ ជម្ពាស្រូវតែត្រូវទឹកភ្លៀងហើយរមែងបែកគុម្ពស្រស់ល្អូតណាស់សុទ្ធឹកល្អ ។ លីប៉ោឃើញតាំងតុលុតជង្គង់ចុះគំនាប់ដូច្នោះ ក៏ភ័យណាស់ស្ទុះទៅឱបលើកតាំងតុឱ្យអង្គុយលើកៅអី ហើយក្រាបគំនាប់ជំរាបថា ខ្ញុំបាទមានមិត្តភក្តិស្រឡាញ់ចង់ចូលមកធ្វើរាជការជាមួយនឹងលោក ដែលលោកមានសេចក្ដីមេត្តាអាណិតខ្ញុំបាទៗ ក៏ឃើញជាក់ច្បាស់អស់ហើយ ខ្ញុំបាទសូមលោកទុកជាបិតាត្រាតែអស់ជីវិត តាំងតុបានស្ដាប់ក៏ជាប់ចិត្តអាណិតស្រឡាញ់លីប៉ោណាស់ ទើបយកការយ៉ាងល្អនឹងក្រសមាសមួយប្រដាប់ពេជ្រមកឱ្យលីប៉ោ ។

តាំងអំពីតាំងតុបានលីហ្ចាមកជួយជាកំឡាំងវេលាណា ការពជការគ្រប់យ៉ាងក៏សំរេចលើតាំងតុ ចាំងអស់ ក៏ការតែកំរើបចិត្តអ្នកក្នុងឆ្នាងពីដើម បណ្ណានាម្ចាស់ទ្រព្យ ត្រូវចំក៏សឹងកោតខ្ចាចអំណាចតាំងតុ ចាំងអស់ ទើបតាំងតាំងចុ៏ងជានាយទាហានធ្វើ តាំងលីហ្ចាជាបុត្រ ចិញ្ចឹមជានាយទាហានស្តាំ តាំងតុក៏លើកព្យុហៈយោធាចូលមកនៅក្នុងទីក្រុង ។

លុះអំណោះតមក លីយូនិយាយទៅតាំងតុថា ពជការក្នុងស្រុកក្រុងសព្វថ្ងៃនេះ ក៏ជាកម្មសិទ្ធិជាច់ខាតលើលោកចាំងអស់ហើយ ប៉ើទ្រឹងគិតប្រការម្តេច សូមឲ្យលោកវ៉ះគិតយ៉ាងស្រួលរហ័សចុះ តាំងតុបានស្តាប់ដូច្នោះ ក៏ឃើញត្រូវផង លុះពេលព្រឹកភ្លឺស្រាង តាំងតុឲ្យលីហ្ចាយុំនាំទាហានមួយពាន់ចូយ ចូលទៅឡោមព័ទ្ធនៅក្នុងព្រះបរមរាជវាំង ឯតាំងតុក៏ចូលទៅក្នុងទីព្រះរាជរោងរម្យ ជួបជុំសេវាកាមាត្យមុខមន្ត្រី តាំងតុឲ្យរៀបលៀងគោជនាហារចំណីបរិភោគក្នុងទីព្រះគំនាល់នោះ លុះរៀបចំរួចស្រេច តាំងតុក៏ការគ្រប៉ីឈរកណ្តាលទីប្រជុំហើយស្រែកប្រកាសថា ហាងជូ ១ គ្មានសតិបញ្ញាសោះ ទ្ធឹងបណ្តាយឲ្យសោយរាជ្យតទៅមិនបាន យើងត្រូវដកហូតចេញ ហើយតាំងហាងជូ ២ ជាព្រះអនុជ ឲ្យឡើងសោយរាជសម្បត្តិជាថ្មី ព្រោះមានសេចក្តីធ្វើវិធ្ងាតរាងវ៉ៃ ប៉ើ

អ្នកឯណាមិនចុះចិត្តយល់ព្រមតាមយើងទេ យើងនឹងសម្លាប់ចេញឥឡូវ
នេះ នាហ្មឺនទាំងអស់ក៏នៅអង្គុយតែស្ងៀម ៗ

នៅក្នុងទីប្រជុំនោះមានមន្ត្រីម្នាក់ឈ្មោះអួនសៀវ ក្រោកឈរឡើង
ស្រែកតបទៅថា ហាងដូពៀនជាព្រះរាជបុត្រឯកព្រះចៅឡូនកេ ជា
ព្រះវររាជបិតាបានលើករាជសម្បត្តិឲ្យហាងដូពៀនជាស្រេចដាច់ខាតហើយ
វេលានេះក៏ព្រះអង្គមិនមានសេចក្តីខុសអ្វី ហេតុម្តេចក៏ខ្លួនអាចហានចេញ
សំដីថានឹងដកហូតចេញ ហើយលើកហាងដូហៀបជាព្រះរាជបុត្រទី ២
ឲ្យសោយរាជសម្បត្តិវិញ ឬខ្លួនមានប្រាជ្ញានឹងគិតក្បត់ផែនដី ៗ តាំងតុ
ក្កដូច្នោះខឹងណាស់ឆ្លើយថា រាជសម្បត្តិសព្វថ្ងៃនេះ នៅក្នុងកណ្តាប់ដៃ
យើងអស់ហើយ យើងយល់ថាមិនត្រូវ ទើបធ្វើឲ្យត្រូវឡើងវិញ បើខ្លួន
រឹងទទឹងមិនស្តាប់យើង ចូរក្រឡេកមើលមុខគ្រប់ដែលយើងកាន់នេះ
មុតឬទេ ៗ អួនសៀវតបថាយើងក៏មានគ្រប់កាន់ដូចខ្លួនដែរ បើខ្លួនមិន
ស្តាប់ហ៊ានតាំងដូហៀបឲ្យខុសពីសណ្តាប់បុរាណរាជប្រវេណី ចូរក្រឡេក
មើលមុខគ្រប់ដែលយើងកាន់នៅដៃនេះ ទឹងមុតឬមិនមុតសោត តាំងតុ
ក្រេវក្រោធខ្ទង់ក ឡាំង តាំងតែហូតគ្រប់គិតនឹងសុះទៅកាប់អួនសៀវ
លីយូឃើញដូច្នោះសុះចូលទៅឃាត់ហើយរៀបថា យើងប្រជុំនឹងគិតការ
ធំបែក ៗ បើមកឈ្លោះជជែកដល់ចាក់កាប់គ្នាដូច្នេះ ការដែលគិតនោះ
នឹងមិនបង់អសារទេឬ ៗ តាំងតុស្តាប់លីយូហាមឃាត់ក៏បាត់មាត់និយាយ

ដ៏អួនសៀវក៏លាបណ្ណានាហ៊ីនតូចធំទាំងឡាយ ការនៅគ្រប់ដើរចេញទៅ ហើយ នាំពួកពលទាហានលើកចេញទៅនៅក្នុងគីដ៏រ ។

ចំណែកតាំងតុនិយាយនឹងអួនង៉ុយជាមាចថា អួនសៀវនោះអង់ អាចវ៉ាងទទឹងនឹងយើងណាស់ នេះដួនឆ្នាយើងបានគិតដល់មា ប៉ើកុំមាន ម្ចាមកនៅក្នុងទីនេះផង យើងនឹងសម្លាប់ចេញមួយរំពេចដែរ យើងគិត ការតាំងអម្ចាលនេះតើយល់ថាខុសឬត្រូវម្តេចខ្លះ ។ អួនង៉ុយឆ្លើយថា ដែលលោកជាធំគិតនឹងត្រឡប់ផែនដីចេញនោះត្រូវហើយ តាំងតុថា បណ្ណានាហ៊ីនមុខមន្ត្រីតូច-ធំទាំងពួង ប៉ើនរណាវ៉ាងទទឹងនឹងយើងដូចយ៉ាង អួនសៀវហើយ យើងនឹងសម្លាប់ចេញតម្លៃនេះ នាហ៊ីនទាំងអស់ពុ ដូច្នោះក៏គោតខ្ទាចតាំងតុ ទើបធ្លាកចាលោកគិតការដូច្នេះ ខ្ញុំបានក៏យល់ ឃើញដូចលោកទាំងអស់គ្នា លុះបរិភោគអាហារហើយ ក៏លាទៅកាន់ ទីលំនៅវៀងខ្លួន ។

ឯតាំងតុនៅក្នុងទ័ពគ្រាលនោះ លុះនាហ៊ីនទាំងពួងចេញទៅអស់ហើយ ក៏សួរបៀវតីនឹងដោ៉ាងថា អួនសៀវលើកពលទៅនៅស្រុកគីដ៏រនោះ ប្រហែលជានឹងគិតការយ៉ាងណាខ្លះ? ចៀវតីឆ្លើយថា អួនសៀវទៅ ត្រានេះដោយអំណាចកំហឹង ប្រហែលនឹងគិតធ្លាធ្ងំពុំខាន ។ មួយ ទៀត សែអួននោះតែងបានជានាហ៊ីនតាមកចំនួន ៤ ជួរមនុស្សហើយ អាណាប្រជានុកូ្ល គ្រប់ខ្ទ្រ ត្រខ ណ្ណសឹងប្រកាន់ខាងអួនសៀវជាច្រើន

ចិត្តអ្នកសៀវក៏មានមានៈណាស់ មុខជានឹងគិតបញ្ចុះបញ្ចូលអ្នកស្រុក ហើយតាំងខ្លួនជាធំនៅក្នុងតំបន់ណាមួយមិនខាន ប្រហែលជាលោកនឹងបង្ក្រាបមិនបានទេ បើដូច្នេះសុំឲ្យលោកមានសំបុត្រព្រះតម្រាស់ចេញទៅតាំងអ្នកសៀវជាចៅហ្វាយកខែត្រមួយ នោះប្រហែលអ្នកសៀវនឹងនៅជាប្រក្រតីវិញ ។

ចៅទេងឆ្លើយថា អ្នកសៀវនោះជាមនុស្សមានគំនិតណាស់ តែថានឹងគិតការអ្វីមិនស្រួលផុះផាយទេ បើលោកមានសំបុត្រព្រះតម្រាស់ទៅតាំងជាចៅហ្វាយស្រុកហើយ បំដូចយើងបងចិត្តពស្តុក អ្នកសៀវនោះក៏នឹងអស់ចិត្តតតតរហានទន្ទាដល់លោកផង ។ តាំងតុស្តាប់ឃើញត្រូវក៏ទៅតែងសំបុត្រជាព្រះតម្រាស់ ហើយចាត់ប្រើទាហានឲ្យកាន់ទៅប្រគល់ដល់អ្នកសៀវ តាំងអ្នកសៀវជាចៅហ្វាយស្រុកពុតវៃហ បណ្តានាហ្មឺនតូច-ធំក៏នៅក្នុងបង្ក្រាបបញ្ជាតាំងតុទាំងអស់ ។

លុះនៅយូរមកតាំងតុឲ្យអញ្ជើញហាន់ដូតៀនចេញមកកាន់ទីព្រះតំ-នាល់ឈ្មោះព្រះទីនាំងកែងដឹកទៀន ហើយឲ្យប្រជុំនាហ្មឺនមុខមន្ត្រីតូច-ធំឆ្លូបជុំក្នុងទីនោះ តាំងតុក៏កាន់គ្រប៉ីឈរប្រកាសថា សព្វថ្ងៃនេះ គាញសិទ្ធិនៅលើដៃយើងហើយ យើងឃើញថាហាន់ដូតៀនមានសតិបញ្ញាតិចមិនគួរស្ថិតនៅក្នុងរាជសម្បត្តិបានសោះ យើងពាំគ្រោះឃើញថាហាន់ដូ-ហៀនមានសតិបញ្ញាកន្លៃគួរនឹងគ្រងផែនដីជាព្រះមហាក្សត្រសោយរាជ-

សម្បត្តិតទៅ បណ្ដានាហ្មឺនទាំងពួងក៏គ្មាននរណានឹងឆ្លើយទាស់ថាប្រការម្ដេច ទើបតាំងគុបង្គាប់ឲ្យពួកខន្ទីពាហ៍ងដូរៀនចេញចាកទីព្រះគំនាល់ ហើយដកហូតយកត្រាស្រមាប់រាជសម្បត្តិ ដែលចងនឹងព្រះសុវង់ហាងដូរៀននោះចេញ ហើយឲ្យហាងដូរៀនគាល់តាមតំណែងព្រះរាជបុត្រនៃអម្ចាស់ផែនដី ហើយបង្គាប់ឲ្យយកខ្លួនព្រះនាងហោហៅ មកដកហូតគ្រឿងប្រដាប់ស្រមាប់ដំណែងយស ព្រះវររាជជននីនោះចេញទាំងអស់ វេលានោះព្រះនាងហោហៅនឹងហាងដូរៀន ក៏មានសេចក្ដីបរិទេវនាការទ្រង់ព្រះកន្សែងសោកាទាំង ២ អង្គ បណ្ដានាហ្មឺនតូចធំដែលជួបជុំនៅទីនោះទាំងប៉ុន្មាន លុះបានឃើញដូច្នោះក៏ខ្សឹកខ្សួលក្តួលចិត្តអាណិតជាទុក្ខស្រក់ទឹកភ្នែកទាំងអស់គ្នា ។

តេងគួនជានាហ្មឺនសុចរិតបានពិនិត្យឃើញដូច្នោះ ក៏ទោមនស្សក្ដៅចិត្តណាស់ក្រោកឈរឡើងស្រែកថា អាតាំងគុនេះជាសត្រូវរាជសម្បត្តិ វាគិតកំចាត់ដកហូតស្ដេចជាអម្ចាស់ផែនដីតាមអំពើចិត្តវា ចាហើយក៏កាន់ដាវស្ទុះ ម្នីម្នាទៅនឹងកាប់តាំងគុៗ ឃើញដូច្នោះ មានបញ្ជាឲ្យពេជ្ឈឃាដត្រូតចាប់យកខ្លួនតេងគួនទៅសម្លាប់ ឯពួកពេជ្ឈឃាដក៏ត្រូតចាប់ខ្លួនតេងគួនបាន តេងគួនមិនមានភ័យភិតតក់ស្លុតរន្ធត់ខ្លាចស្លាប់សោះ ថែមទាំងស្រែកជេរទ្រគោះជាពាក្យគ្រោះគិះដៀលតាំងគុ ទាល់តែពេជ្ឈឃាដនាំទៅដល់ទីកន្លែងពឃាដសូន្យជីវិតទើបបាត់មាត់ ។ (មា៩៣)

ត្រៃកូដធម៌

វិជ្ជាធម្មទេសនា ព្រះចាស្ទាត់ចក្ខុមណីវ៉ាត សុផុសារ៉ា វត្តលង្កា

នមោ តស្ស ភគ្គវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះ ព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមង់ត្រង ព្រះធម៌ហើយនឹង ព្រះអរិយសង្ឆ ដោយគោរព) ។

លោកនេះអាត្មាភាពសូមដកស្រង់យកធម៌ប៉ីយ៉ាង គឺ: សច្ចំ សេចក្ដីពិតត្រង់ ១, ១ន្ទ្ធ សេចក្ដីអត់ធន់ ១, កតញ្ញូតា សេចក្ដីដឹងគុណ ១, ធម៌ទាំងប៉ីនេះមានសំដែងជាបុគ្គលាធិដ្ឋាន ក្នុងគម្ពីរមហាបដ្ឋាន ត្រង់សរូបចតុព្ពីសតិបដ្ឋានៗ: ជាធម្មសវនាការដូចតទៅនេះ:

ធម៌ទាំងប៉ីគឺ:សច្ចំ, ១ន្ទ្ធ, កតញ្ញូតានេះ ឈ្មោះថាត្រៃកូដធម៌ ឬ១ត្តមវរធម៌ ឬថា បធានធម៌ ព្រោះធម៌ជាកំពូលនៃលោកឬប្រសើរវិសេសជាងធម្ម្ជាតជាងធម៌ទាំងពួង ។

សេចក្ដីអធិប្បាយ

ទី ១ – សច្ចំ សេចក្ដីពិតត្រង់ គឺមិននិយាយបំផ្ងើសឲ្យលើសពីសភាវៈពិត បើឃើញថាឃើញ ១ុសថា១ុស, ត្រូវថាត្រូវដូច្នេះជាដើម ហៅថាសច្ចៈ:សេចក្ដីពិត បើសំដែងដោយ១ត្ថិដ្ឋបានដល់អរិយសច្ចទាំង ៤, ពាក្យថា អរិយសច្ចនេះប្រែថា សេចក្ដីពិតរបស់ ព្រះអរិយបុគ្គល, សេចក្ដីពិតឥតស្ល្ជ្ជ ១ងមាន ២ យ៉ាងគឺ: ១ – ១ុក្ខ: សេចក្ដីត្រូវលំបាក,

២-សមុទយៈ: កំណើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខ, ៣- និរោធៈ: សេចក្តីរលត់ទុក្ខ ឬធម៌សម្រាប់រំលត់ទុក្ខ, ៤- មគ្គៈ: ផ្លូវឬឧបាយនៃសេចក្តីរលត់ទុក្ខទាំង៤យ៉ាងនេះ: ជាសច្ចៈពិតតតមានស្ត្រីនិងនិងបំបែរពីជាមិនពិតទេវិញពុំបានឡើយ ។

ក៏សច្ចៈធម៌នេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងដោយពិស្តារក្នុងសុត្តន្ត-បិដក គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ត្រង់ចង្កីសូត្រ ក្នុងសូត្រនោះមានសេចក្តីដំណាលថា: មានមាណពម្នាក់ឈ្មោះកាមទិត: មានក្បាលរោការលឿងមានអាយុ ១៦ ឆ្នាំពីកំណើត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិយណ្ឌនឹងគម្ពីរកេដុភ: ព្រមទាំងអក្ខរប្ជកេ១ គឺសិក្ខានឹងនិរុត្តិដែលមានគម្ពីរតតិហាសៈជាគំរប់ ៤ ជាអ្នកស្គាល់ទូរ១ទ១ទ១ងវេយ្យាករណ៍ជាអ្នកមិនមានទោសទ១ យ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ ទ១ងមហាបុរិស-លក្ខណព្យាករណសាស្ត្រ, ឯ១ងសួរពីធម៌ដែលនាំឲ្យកើតសច្ចៈចំពោះ ព្រះមានព្រះភាគ។ ទ្រង់ឆ្លើយតបថា: ម្នាលកាមទិត: សច្ចៈគឺសេចក្តីពិត ត្រង់កើតឡើងដោយអាស្រ័យការព្យាយាម។ កើតឡើងដោយអាស្រ័យការពិចារណា។ កើតឡើងដោយអាស្រ័យការប្រឹងប្រែង។ កើតឡើងដោយអាស្រ័យនូវការពេញចិត្ត។ កើតឡើងដោយអាស្រ័យការចូលចិត្ត ធម៌ក្នុងគំនិត។ កើតឡើងដោយអាស្រ័យការពិចារណានូវអត្ថ។ កើតឡើងដោយការចេះចាំនូវធម៌ ។ កើតឡើងដោយអាស្រ័យការស្តាប់ធម៌។

កើតឡើងដោយអាស្រ័យការធ្លាប់ត្រេកត្រអប់ស្តាប់ៗ កើតឡើងដោយ
អាស្រ័យការចូលទៅអង្គុយជិត ។ កើតឡើងដោយការចូលទៅរក ។
កើតឡើងដោយអាស្រ័យសទ្ធាសេចក្តីជឿ: បើបុគ្គលណាគ្មានសទ្ធា
ហើយ ការចូលទៅរកក៏មិនមាន, ការចូលទៅអង្គុយជិតក៏មិនមាន, ការ
ធ្លាប់ត្រេកត្រអប់ស្តាប់ក៏មិនមាន, ការស្តាប់ធម៌ក៏មិនមាន ការចេះចាំនូវ
ធម៌ក៏មិនមាន, ការពិចារណានូវអត្ថក៏មិនមាន, សេចក្តីចូលចិត្តធម៌ក្នុង
គំនិតក៏មិនមាន, ឆន្ទៈការពេញចិត្តក៏មិនមាន, ការប្រឹងប្រែងក៏មិនមាន;
ការពិចារណាក៏មិនមាន, សេចក្តីព្យាយាមក៏មិនមាន, សច្ចៈសេចក្តីពិត
ត្រង់ក៏មិនមាន, បុគ្គលខោះលែងស្គាល់ខុសត្រូវ, គុណទោស, បុណ្យ-
ចាប លុះទៅក្នុងអំណាចនៃលោភៈ, ទោសៈ, មោហៈ ការណ៍ដែលមិន
ពិតហ៊ានថាពិត, សេចក្តីខុសហ៊ានថាត្រូវ គិតឃើញតែប្រយោជន៍
ផ្ទាល់ខ្លួន មិនឃើញសេចក្តីទុក្ខរបស់អ្នកដទៃ; មនុស្សប្រភេទនេះនឹងក្លាយ
ខ្លួនទៅជាអាប្ជ្ញសក្ខីបុគ្គល រកសួគ៌និព្វានឈានសមាបត្តិមិនឃើញឡើយ,
ពីព្រោះសត្វសត្វ ទាំងអស់ក្នុងពិភពលោក ដែលមានមុខឆ្ពោះសញ្ជ្ញរទៅ
រកវឌ្ឍនធម៌ចាន ដោយសារតែមានសច្ចៈជាចន្ទ្រាលដួយ ។ បើ
ប្រាសចាកសច្ចៈហើយ នឹងរកវឌ្ឍនធម៌មិនឃើញឡើយ ។ ដូចជា
ក្នុងលោកសត្វនៃនេះ បើប្រទេសណាមិនមានសច្ចៈធម៌ដាស់គ្នានឹងគ្នា គឺ
ពួកពលរដ្ឋគ្មានសច្ចៈពិតត្រង់ចំពោះ ព្រះមហាក្សត្រនឹងពួកសេវកាមាត្យ ។

ក៏គ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនឹងពលរដ្ឋទេ ប្រទេសនោះ
មិនអាចធានាធ្លាការបរិបូណ៌ដោយមហិទ្ធិរិទ្ធិឡើយ មុខជានឹងស្គមស្ងួត
ឥតបុទ្ធិអំណាចពួកវិទេសជនចាំងឡាយ នឹងជិះជាន់ក្រសេរជញ្ជក់យក
សាច់ឈាម នឹងក្លាយទៅជាប្រទេសទាបទាសទុព្ភលភាពមិនខាន ។

មួយទៀតសម្ព្ធីមាតាបិតានឹងបុត្រាបុត្រី ស្វាមីនឹងភរិយា ឬក៏គ្រូ
ឬបដ្ឋាយាចារ្យនឹងសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់ទៅវិញទៅមក
ទេ សេចក្តីវិនាសតែងកើតឡើងជ្រាកដដល់ជនចាំងឡាយនោះ ។ សច្ចៈ
ធម៌នេះជាគុណ ប្រសើរបំផុតក្នុងលោកបានជាព្រះសម្ពុទ្ធជាអគ្គបុគ្គលទ្រង់
សំដែងថា: **សចេ ហិ ឋានំ លោកេ សចេ លោកេ
ឧត្តមកំ សចេ ធម្ម ជ្ជមានស្ម សត្ថុ ឧ ញ្ញ ជ្ជ ។**
សេចក្តីថាសច្ចៈជាធម៌ដ៏ត្ត្ថមក្នុងលោក សច្ចៈជាប្រធានក្នុងលោក ក៏ពុណ្ណ
ចាំងអស់រមែងមានក្នុងសច្ចៈ ។ បើប្រាសចាកសច្ចៈហើយបុណ្ណក៏មិន
មាន បើគ្មានបុណ្ណហើយ រមែងបានដួលតែនឹងសេចក្តីទុក្ខលំបាកលន្ងន់ខ្លាំ
ក្រ ក្រៅចាកឥតជានិច្ច; ព្រោះហេតុនោះលោកអ្នកសប្បុរសចាំងឡាយ
គួរទំ ញ ាំ ងសច្ចៈគឺសេចក្តីពិតត្រង់ឲ្យកើតមានឡើងគ្រប់ៗ គ្នា ។

ទី ២ - ១ន្ត ី សេចក្តីអត់ធន់ទ្ទ ុ ក ជ ាចន្ទ ល ់ ទ ី ពីរ ស ម្រ ាប ់ ទ ល ់ ទ្រ ូ ស ួ យ
សត្ត ូ ឲ្ យ ម ាន ម ុ ខ ឆ្ព ោ ះ ទ ៅ ក អ ា រ យ ធ ម ; ១ ន ្ត ី (ប ្ រ ៃ ថ ា ស េ ច ក ្ ត ី អ ត ់ ជ ា ត ូ ន ឹ ង ឥ ត ិ ក ្ ខ ា

ប្រៃថាសេចក្តីធន់ សព្វគាំងពីរនេះមានសេចក្តីជាមួយគ្នា ទើបរួមចូលគ្នា ហៅថាសេចក្តីអត់ធន់ សេចក្តីអត់ធន់នេះលោកចែកជាបីយ៉ាងគឺ:

១ – អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោភ:,

២ – អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតទោស:,

៣ – អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតមោហ: ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោភ:នោះបាន ទាងការអត់ទ្រាំនឹងចំណង់ផ្សេងៗដែលកើតឡើងក្នុងទ្វារទាំង៦ ។ ពាក្យ ថាអត់ទ្រាំគឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្តីស្រេកឃ្លានទេ ។ បុគ្គលចំពួកខ្លះព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ ឬសេចក្តីស្រេកឃ្លាន បានជាហ៊ានលួចឆក់ដណ្តើមបំបាត់ប្រវ័ញ្ជ៍ទ្រព្យសម្បត្តិរបស់គេ កាលបើ ប្រព្រឹត្តដូច្នោះ រមែងជួបប្រទះនឹងសេចក្តីទុក្ខព្រួយដែលជាផលរបស់ទុច្ច-រិតនោះ ។ មានត្រូវគេសម្លាប់គុកច្រវ៉ាក់ជាដើម ។ បុគ្គលណាជាមនុស្ស មិនសូវរវល់ពីមនោ ចេះអត់ទ្រាំបាន បុគ្គលនោះឯងតែងប្រកបដោយ សុខ្ចកាត់ទ្រឹងអនាម័យដ៏ល្អ ។ ១ន្ត្ថ សេចក្តីអត់ធន់ប្រភេទនេះ ហៅថាអត់ធន់ ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោភ: ។ ចំណែកអត់ធន់ចំពោះសេច-ក្តីទុក្ខដែលជាហេតុឲ្យកើតពាគ: ។ ត្រូវសម្រាប់ចូលក្នុងន១ន្ត្ថនេះដែរ ។ ឯ សេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតទោស:នោះ បាន ទាងសេចក្តីអត់ធន់ទ្រាំនឹងពាក្យប្រកាន់ ដែលបុគ្គលដទៃស្តីថា ១ៈគន់ឫគ្នុ:

តិះដៀល ឬអត់ធន់ទ្រាំអំពើដែលបុគ្គលដទៃបៀតបៀនដែលជាហេតុឲ្យកើតទោស: ។ ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ ដែលចាមិនឲ្យគេស្តីថាមិនឲ្យគេរិះគន់ ឬតិះដៀលនោះគ្មានទេ, អម្បាលព្រះអាទិត្យ ព្រះចន្ទ ដែលធ្លុះបំភ្លឺលោកជាប្រក្រតី ម្តេចក៏គង់មានគេតិះដៀលខ្លះដែរ, ចំណាន់បើមនុស្សក្នុងលោកនឹងរកនរណាឲ្យជាមនុស្សគ្មានគេតិះដៀលនោះមិនមានឡើយ; ទុកជាព្រះសាស្តាបរមគ្រូជាម្ចាស់ដែលប្រកបដោយព្រះមហាករុណាគុណ ក៏គង់មានគេតិះដៀលខ្លះដែរ; បើយល់ឆាក់យ៉ាងនេះហើយគួរឲ្យមានទន្ទីអត់ធន់ក្ងុ:ត្រាធទ្ធ ។ ឬបានណាចារ្យទាំងឡាយ លោកសំដែងប្រាប់ៗបាយ គឺយោបល់ជាគ្រឿងរំលត់សេចក្តីត្រាធទ្ធថា: "ទុកជាមានក្ងែកក្ងីក៏ត្រូវធ្វើដូចជាងងឹត, មានត្រចៀកស្តាប់ឮ ក៏ត្រូវធ្វើដូចជាឮ" ដូច្នេះទើបអត់ធន់សេចក្តីត្រាធទ្ធនោះបាន, ប្រសិនបើធ្វើជាមនុស្សក្ងែកទ្ធ្ងីតត្រចៀកទ្ធ្ងី ចេះតែឃើញចេះតែតុ. ហើយនៅជាបុថុជនចំគ្ត្រាលធ ក ន ន ន ក ្ យ ា ១ ន្ទ ី សេចក្តីអត់ធន់នោះបានដោយកម្រណាស់ ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតមោហ:នោះបានខាងសេចក្តីអត់ធន់នឹងទុក្ខវេទនាធ្ងន់ ។ ដែលកើតឡើងក្នុងកាយនឹងចិត្ត មិនលុះក្នុងអំណាចទុក្ខវេទនា ហើយនៅប្រព្ឹត្តទុច្ចរិតឡើយ ។ សូម្បីការដែលអត់ទ្រាំនឹងទុក្ខវេទនាក្នុងរោគ ឈ្ងាត់នោះសោត ក៏ជា

ហេតុដូច្នេះ បុគ្គល ឲ្យមានសតិសម្បជញ្ញៈ គឺសេចក្ដីភ្ញាក់រឭកនឹងសេចក្ដី
ដឹងខ្លួន ដែលជាគុណវិសេសគួរឲ្យមានគ្រប់កាលទាំងពួង, ពុំនោះសោត
ក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានទុក្ខយ៉ាង
មាំមួនខានមិនបានឡើយ ។ ព្យាធិដែលនឹងឲ្យកើតទុក្ខក្នុងវេលានោះ
គឺត្រូវគិតឲ្យឃើញតាមសេចក្ដីពិតថា ព្យាធិនឹងមរណៈនោះ ជាទុក្ខដែល
សត្វទាំងឡាយត្រូវតែជួបប្រទះពាល់ៗគ្នា គេចមិនរួចឡើយ; ក្នុងអភិណ្ហ-
ប្បច្ចវេក្ខណៈ ដែលព្រះបរមសាស្ដាទ្រង់ប្រដៅឲ្យនឹករំពឹងជារឿយៗ ថា:
"ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញមានជម្ងឺជម្ងាត់
ជាធម្មតា នឹងចៀសវាងជម្ងឺជម្ងាត់មិនបានឡើយ" ដូច្នេះនោះ ក៏គប្បី
ឲ្យប្រឹងខ្លួនអំពីកាលដែលនៅជានៅឡើយ, បើចាំទៅនឹករំពឹងក្នុងពេល
ដែលជម្ងឺជម្ងាត់មកដល់តែម្ដង ក៏មុខជាកម្រនឹងបាន, ព្រោះវេលាដែល
ឈឺនោះឯងតែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់; កាលបើអត់
ទ្រាំទុក្ខវេទនាមិនបាន សតិសម្បជញ្ញៈក៏នឹងទ្រេតទ្រោតទៅមិនតាំងនៅ
ខ្ជាប់ឡើយ, ដូចជនពំពួកខ្លះដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជា
នោះ លុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ ក៏ច្រើនតែមានចិត្តរវើ-
រវាយឆ្វេងៗ ដរាបដល់ធ្វើអំពើទុច្ចរិតមានសម្លាប់សត្វជាដើម ដើម្បី
បូជាគ្រោះ ដោយចង់រស់តែខ្លួនឯង មិនគិតករុណាសត្វដទៃក៏មាន ។
ព្រោះហេតុដូច្នោះ ការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតី ដើម្បីឲ្យកើតខន្តី

នោះ ជាកិច្ចដែលយើងត្រូវការគ្រប់ៗ ប្រាណសម្រាប់តយុទ្ធនឹងសត្រូវ គឺព្យាធិទុក្ខ គ្រប់វេលាដែលជិតនឹងដល់មរណៈទុក្ខនោះ ។ ចំណែកអ្នកដែលមានប្រាជ្ញារៀនកេងរកគាតទ្រព្យ នឹងវិទ្យាសាស្ត្រ មានអក្សរសាស្ត្រ ក្សេត្រសាស្ត្រ នឹងពាណិជ្ជកម្ម កសិកម្មជាដើម បើមានខន្តីអត់ធន់នូវការស្រេកឃ្លាន មានក្រ ក្តៅត្រជាក់ជាដើមហើយ វិជ្ជានឹងគាតទ្រព្យ គឺរមែងសម្រេចដល់បុគ្គលនោះដោយមុហុត្តភាព បុគ្គលនោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សចំរើនលោកបាន ។ ម្យ៉ាងទៀតអ្នកដែលមានខន្តីរមែងជាទីប្រិយនៃទេវតានឹងមនុស្សទាំងឡាយ, សមនឹងពុទ្ធភាសិតថា:

ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ "អ្នកមានខន្តី ជាអ្នកមានមេត្តា ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកមានខន្តីរមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតានឹងមនុស្សទាំងឡាយ" ។ ខន្តីនេះជាគុណធម៌ប្រសើរបំផុតក្នុងលោក ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថា: ខន្តិ ហិ បរមំ លោកេ ខន្តិ លោកេ បជានតា ខន្តិយា វិជ្ជមានាយ សព្-ពញ្ញូ វិជ្ជតិ ។ សេចក្តីថា "ខន្តីជាធម៌ដ៏ឧត្តមក្នុងលោក ខន្តីធម៌ជាប្រធានក្នុងលោក គឺបុណ្យទាំងអស់មានដោយសារខន្តី" ។ បើប្រាសចាកខន្តីហើយរមែងជួបតែនឹងសេចក្តីទុក្ខ លំបាកក្រៃក្រ ចោក

ទាបជាទិដ្ឋ; ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយ គួរខំចំរើនខន្តិធម៌ឲ្យមានឡើងគ្រប់ៗគ្នា ។

ទី ៣– កតញ្ញូតា សេចក្ដីដឹងគុណទុកជាបន្ទល់គំរប់បស់ស្រោមទល់ទៅលើកសត្វឲ្យដល់នូវអនាគតកាលដ៏ល្អ ។ កតញ្ញូតាធម៌ជាគូនឹងកតវេទិតាធម៌ គឺបើដឹងថាអ្នកណាមួយមានគុណដល់ខ្លួន ហើយត្រូវធ្វើគុណតបអ្នកនោះវិញ បើគ្រាន់តែដឹងៗ តែប៉ុណ្ណោះ គឺមិនអាចញ៉ាំងប្រយោជន៍ឲ្យសម្រេចបាន ដូចជាដឹងថាព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, មានគុណជាអនន្តចំពោះសព្វសត្វទាំងអស់ក្នុងត្រៃលោក សត្វទាំងនោះគួរតែតាំងចិត្តឲ្យស្មោះចំពោះព្រះពុទ្ធ; ព្រះធម៌, ព្រះសង្ឃយកជាទីពឹងទីរឭកស្មើដោយជីវិត ទាំងខំប្រតិបត្តិតាមឱវាទរបស់ព្រះសម្ពុទ្ធជាម្ចាស់ ពុំប្រព្រឹត្តកន្លងដូច្នេះជាដើម ឈ្មោះថាមានកតញ្ញូកតវេទិតាធម៌ចំពោះព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ; ព្រមទាំងដឹងគុណចំពោះបុព្វការីទាំងឡាយមានមាតាបិតាជាដើម ត្រូវតែរក្សាដោយស្មោះស្ម័គ្រ បើលោកមិនទាន់មានសទ្ធា, សីលៈ, ចាគៈ, បញ្ញា គប្បីឲ្យមានឡើង: បើបុគ្គលណាមួយប្រកបដោយកតញ្ញូកតវេទិតាធម៌ដូច្នេះហើយ បុគ្គលនោះឈ្មោះថាបិទទ្វារនៃអបាយទាំង ៤ មាននរកជាដើមនឹងបានប្រកបដោយសុខគតិអនាម័យដ៏ល្អ ។ បុរាណបណ្ឌិតទាំងឡាយមានព្រះសម្ពុទ្ធជាដើមដែលទ្រង់ស្វែងរកគន្លងសុខ លោក

មិនដែលលះបង់នូវកតញ្ញូកតវេទិតាធម៌នេះឡើយ ។ ដូចកាលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សោយព្រះជាតិជាស្តេចសេក ជួនជាប្រកបដោយ[illegible] ទៅជាប់លប់អ្នកស្រែហើយបានត្រឡប់របស់ជីវិតឡើងវិញ ក៏ដោយសារតែគុណនៃកតញ្ញូកតវេទិតាធម៌ ។

មួយទៀតក្នុងប្រទេសនីមួយៗ ពួកពលរដ្ឋទាំងឡាយត្រូវមានកតញ្ញូកតវេទិតាធម៌ចំពោះព្រះមហាក្សត្រ ស៊ូយកកម្លាំងកាយនិងកម្លាំងទ្រព្យជួនធ្វើជាពលី ក្នុងពេលដែលកើតអសន្តិសុខម្តងៗ ក្នុងប្រទេស ហើយត្រូវស្រឡាញ់ព្រះមហាក្សត្ររបស់ខ្លួនស្មើដោយជីវិត, ត្រូវដឹងគុណពួកសេវកាមាត្យទាំងឡាយ ដែលបានតែងតាំងច្បាប់ ឲ្យប្រតិបត្តិ ដើម្បីបានសេចក្តីសុខចំរើន, បើពួកសេវកាមាត្យទាំងនោះមានកើតអាសន្ន ដោយហេតុណាមួយត្រូវជួយដោយស្មោះស្ម័គ្រ ទាំងខំប្រតិបត្តិតាមច្បាប់ ពុំហ៊ានប្រព្រឹត្តក្នុងផ្លូវ[illegible]ជាដើម ឈ្មោះថាមានកតញ្ញូកតវេទិតាធម៌ចំពោះសេវកាមាត្យ ។ ត្រូវប្រកបដោយមេត្តាករុណាប្រណីចំពោះពលរដ្ឋទាំងសកលរដ្ឋ ត្រូវកាន់សច្ចៈនិងខន្តិឲ្យខ្ជាប់ កុំលុះក្នុងអំណាចនៃអគតិធម៌ទាំង ៤ មានឆន្ទាគតិជាដើម ។

ក៏ធម៌ទាំងបីគឺសច្ចំ, ខន្តិ, កតញ្ញូតានេះ បើមាននៅឃុំ, ស្រុក, ខេត្ត ប្រទេសណាហើយ ឃុំ, ស្រុក, ខេត្ត, ប្រទេសនោះនឹងសម្បូណ៌ដោយ

ខ្លួនគាត់ ឆាត់ធំល្អណាស់ឡើងមានឫទ្ធិទ្រ ដោយមហុត្តកាល មិន អាចក្លាយទៅជាប្រទេសទាបទាសស្ត្រីទេឡើយ, ដូចកុំសំពៅស្ក ដែលមានទំពាស់ ៨ ហ៊ុន ២ ពាន់យោជន៍ ខ្ពស់ស្កឹមស្កែលេចទៅក្នុងទឹក-លំយ នោះបីមានខ្យល់ព្យុះពេញមាបក់បោកមកអំពីទិសទាំង ៨ ក៏មិនអាចញាំញីផ្ដើកនោះឲ្យញាប់ញ័របានឡើយ ដោយមានឫសបំពង់ទ្រទប់ពីក្រោមយ៉ាងណាមិញ ត្រៃកូដធម៌ទាំងបី ទុកដូចជាចំនុលទល់ទ្រសត្វក្នុងពិភពលោកមិនឲ្យអន្តរាយទៅកើតហ៊ីនភាពក៏ដូច្នោះដែរ ។

ឯត្រៃកូដធម៌នេះកុំនិយាយឡើយដល់ទៅមនុស្សនោះជាតិតិរច្ឆានក៏ដោយ ឲ្យតែបានរក្សានូវត្រៃកូដធម៌នេះដោយទៀងទាត់ប្រាកដ ក៏អាចធ្វើខ្លួនឲ្យក្លាយទៅជាទេវតាបាន ដូចមាននិទានមួយក្នុងពហុលាភារីសូត្រគម្ពីរមហាបដ្ឋាន ត្រង់សរូបចតុពីសតិប្បយការៈ ដំណាលថាៈ មានសត្វបីគឺមេគោ១, កូនគោ១, ខ្លាធំ១, ជាអ្នករក្សានូវធម៌ទាំងបី, មេគោរក្សាសច្ចធម៌, កូនគោរក្សាកតញ្ញូតាធម៌, ខ្លាធំរក្សាខន្តិធម៌, ដោយអំ-ណាចធម៌ទាំងបី សត្វទាំងនោះ ក៏បានទៅសោយទិព្វសម្បត្តិនៅស្ថានត្រៃត្រឹង្សសួគ៌ប៉ុណ្ណោះដោយយសបរិការជាអស្ចារ្យ, រឿងនេះបើចង់ជ្រាបដោយពិស្តារ សូមមើលក្នុងពហុលាភារីសូត្រនោះចុះ; ត្រាទនៃដំណាលមកដោយខ្លីប៉ុណ្ណេះឲ្យឃើញថាធម៌ទាំងបីគឺ សច្ចៈ, ខន្តី, កតញ្ញូតានេះ

មានមហិទ្ធិឫទ្ធិគួរអស្ចារ្យ បើសំដែងដោយខ្លួនក្រែងឃើញថាមានអត្ថដ៏ជ្រៅឆ្ងាយពន់ពេក ។

ន័យមួយទៀត ព្រះសម្ពុទ្ធទ្រង់សំដែងថា: សច្ច: រម្ងាប់លោភ:, ខន្តី រម្ងាប់ទោស:, កតញ្ញុតា រម្ងាប់មោហ: ។

សំដែងមកកាន់ធម៌ទាំងបី គឺ សច្ចំ, ខន្តី, កតញ្ញុតា ដែលហៅថា ត្រៃគុណធម៌: ឬឧត្តមវរធម៌ ឬជាបធានធម៌ ក៏សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ធម្មទេសនានេះផង: ដោយតេជះនៃធម្មទេសនាសូមទេវតាទាំងមួយម៉ឺនលោកធាតុ ពិទ័ក្សរក្សាព្រះប្រិយមហាក្សត្រ ព្រមទាំងព្រះរាជវង្សានុវង្ស សម្ដេចព្រះវររាជបិតា សម្ដេចព្រះវររាជជននីនាថ សូមទ្រង់ប្រសិទ្ធដោយចតុព្វិធពរ គឺ អាយុ, វណ្ណ:, សុខ:, ពល:, បរិបូណ៌ដោយព្រះសតិបញ្ញាបរិហារកម្ពុជប្រទេស ឲ្យបានលុះដល់ឧត្ដមគតិដោយមុហុត្តកាលដ៏ស្រួលរាល់សម័យ: ទាំងសូមបរិស័ទទាំងឡាយគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនវិធី ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធឲ្យបានប្រកបដោយសុខភាពអនាម័យដ៏ល្អ ដើម្បីជាពលរដ្ឋ ប្រកបកិច្ចសាសនាការងារបានមគ្គាក៏សម័យសមតាមអធ្យាស្រ័យរគុបំណាច់កុំបីឃ្លាតឡើយ ។

(ចប់)

ព្រះបាឡាត់ឧត្ដមលិខិត (សុង-ស៊ុរ)

ប្រតិបអាកស៊ុំទ្វីប

ហ្លួងនិពន្ធមន្ត្រីញុក-ថែមប្រែរៀបរៀង

(តមក)

ព្រះរាជទានសេត្រាស់សួរតទៅទៀតថា "បើខ្ញុំនេះមានជីវិតរស់នៅយឺនយូរ ខ្ញុំនេះក៏គង់តែដូច្នេះដែរ. ប្រសិនបើយសោធរាមានជីវិតរហូតដល់ ៨០ឆ្នាំ, សោយក្តីចាស់ជរាធ្វើឲ្យព្រះនាងបានខ្វល់ផលដូចគ្នាយ៉ាងនោះដែរឬ? បាលិន, នាងខេស្យមា, គោតមី, គង្គា, នឹងអ្នកឯទៀតៗ ក៏គង់តែយ៉ាងនោះដែរ? នាយសារថីក្រាបទូលអង្គថា "ត្រូវហើយព្រះអង្គ ៗ ទ្រង់ត្រាស់ថា បើដូច្នោះ ចូរបរោករថត្រឡប់ព្រះរាជវាំងវិញចុះ, ខ្ញុំបានឃើញរបស់ដែលមិនដឹកថា នឹងបានឃើញនោះហើយ" ។

ដោយហេតុទ្រង់ព្រះរំពឹងដល់ភាពដែលទ្រង់បានទតព្រះនេត្រមកនោះ ទើបព្រះសិទ្ធត្ថមានព្រះកាយស្រពោនស្ពេចយាងចូលតំណាក់ដ៏ល្អវិចិត្រ តុតតែ្រតក្រតាល ដោយមានព្រះក្ត្រីសោកសង្ក ហើយមិនទ្រង់សោយទំរស នឹងផ្លែឈើដែលធ្លាប់ប្រើជាព្រះក្រយាសោយ គ្រប់វេលាល្ងាចនោះ ហើយគ្រប់វេលាល្ងាចនោះ ព្រះអង្គមិនទ្រង់ទតពិតពិល រមិលមើលពួកនាងល្ខោនរបាំដែលតោមនៃព្រះរាជវាំងដែលព្យាយាមធ្វើឲ្យព្រះអង្គទ្រង់សម្រើបនោះឡើយ មិនទ្រង់ហើបហាព្រះឱស្ឋនឹងព្រះនាងយសោធរាដែលស្ងួនសុតព្រះទ័យ ក្រាបចុះនឹងព្រះបាទយុគលទូលអង្វរ

សួរថា " ព្រះអង្គនឹងមិនមានសេចក្ដីសុខចំពោះខ្ញុំម្ចាស់ហើយឬ ? ព្រះអង្គត្រាស់ថា " ទេ តើតណ្ហាទេស្នេហា ! សេចក្ដីសុខសម្រាន្តបែបនោះជាសេចក្ដីសុខដែលនាំដួងវិញ្ញាណរបស់បងឲ្យវង់កម្ម កាលនឹកឃើញថាកែតងតែផុតអស់ទៅនៅទីបំផុត ហើយយើងទាំងពីរនាក់ ក៏ត្រូវតែដល់នូវឯកភាព, យសោធរាអើយ ! កាលដល់ការៈអស់កម្រែក ត្រឡប់ក្លាយទៅជាគួរខ្ពើមរអើម, ចយរទ្រុឌកំឡាំងហើយខ្នងកោងចុះទៅទៀត, ពិតមែនណាស់ បើទុកជាយើងមានបណ្ដិតស្នេហាយ៉ាងស្និទ្ធស្នាលក្រៃលែង ស្មើរដកដង្ហើមរួមប្ញល់គ្នាគ្រប់ទិពាត្រី តែកាលវេលាដែលកន្លងទៅៗ តែងដណ្ដើមយកពត៌តណ្ហា របស់បងនិងរបស់នាងឆាប់ទៅជាមួយផង, ប្រៀបដូចព្រៃកាលដ៏ខ្មៅងងឹត តែងលុបលាងស្នាមពណ៌កុលាបដ៏ក្លិនស្រាំងលើផ្កាទាំងនោះដោយអាការសន្សឹមៗ បន្តបុំន្ទងងឹតទៅៗ ដូច្នោះឯង, នេះហើយរបស់ដែលបងបានរកឃើញ ហើយដួងចិត្តរបស់បងទាំងមូលតែងញាប់ញ័ររន្ធត់ដោយសេចក្ដីតឹងតែងបារម្ភដូច្នេះ ហើយដួងចិត្តរបស់បងទាំងមូល រឹតតែកំណែការពារសេចក្ដីស្នេហាឲ្យផុតពីការប៉ះពាល់ នៃកាលវេលាដែលចូលមកពីឃាងផ្ដើមឲ្យកើតវិបាសឆាកដល់មនុស្សលោក " មានព្រះឧង្ការដូច្នេះហើយ ព្រះសិទ្ធត្ថក៏ទ្រង់គង់នៅស្ងប់ស្ងៀមរហូតអស់រាត្រីដោយសេចក្ដីក្រវល់ក្រវាយ មិនអាចផ្ដុំឲ្យលក់ទៅបានឡើយ ។

មួយវិញទៀត ក្នុងរាត្រីកាលនោះ ឯព្រះបាទសុទ្ធោទនៈ មហារាជទ្រង់ព្រះសុបិនយ៉ាងចំឡែកនាំឲ្យកើតរការអួលក្នុងព្រះហឫទ័យ និមិត្តដំបូង ទ្រង់ព្រះសុបិនឃើញទង់ជ័យ ១ គេបង្ហូតឡើងយ៉ាងរុងរឿង មានដួងអាទិត្យផ្ទុះពន្លឺមាសបោលមកព្រាលផ្លោ តែរស្មីព្រះចន្ទផ្ទុះបុះបាំងមក តែតមកមានខ្យល់បក់ផាត់មកទាល់តែទង់ជ័យដ៏ស័ក្តិសិទ្ធិនោះដាច់ដាប ដាប់រម្រៀកៗទៅ ធ្លាក់មកលើធូលីពសុធា, តមកទៀត មានទេវតាហោះចុះមករើសយកទង់ដែលអន្តរាយនោះឡើងវិញ ហើយនាំយកទៅដាក់នៅទិសខាងកើតទ្វារព្រះកុដធានី ។ ព្រះសុបិនជាគំរប់ពីរថា ព្រះអង្គទ្រង់ទតព្រះនេត្រឃើញគជសារ ១០ មានភ្លុកជាប្រាក់ ដើរជ្រួញព្រះធរណីញ័របញ្ជ័រយ៉ាងធូន, ដំរីទាំងនេះដើរមកពីទិសខាងត្បូង អ្នកដែលជិះលើគជសារទី ១ គឺព្រះរាជឱរសរបស់ព្រះអង្គ ដំរីឯទៀតៗ ដើរតាមៗគ្នាមក ។ ព្រះសុបិនជាគំរប់ ៣ ថាមានរថដ៏វិចិត្រដោយរស្មីដ៏រុងរឿងទឹមដោយពាជី ៤ ព្រួសផ្សែងសចេញមកតាមរន្ធច្រមុះ ហើយរំពា-អៀងចេញពពុះមកជាភ្លើង ព្រះសិទ្ធត្ថទ្រង់គង់លើរាជរថនោះ ។ ព្រះសុបិនគំរប់ ៤ ថាមានកង់ដែលវិល, វិលមិនឈប់ មានដុំធាមាសរចនាដោយកែវមណីរត្ន ហើយមានរូបតំទូរយ៉ាងចំឡែកនៅតាមបាមកង់ ហើយកង់នេះខណៈដែលកំពុងវិលនោះ ហាក់ដូចជាកើតជាភ្លើងទីងតទ្រី ។ ព្រះសុបិនជាគំរប់ ៥ ថាមានស្គរធំមហិមា តាំងនៅកណ្ដាល

ផ្ទះរាជ ព្រះរាជធានីនឹងក្ដុ ព្រះរាជបុត្រ ទ្រង់ទ្ងន់ស្ករនេះ ដោយជុំជែក
មានសូរសំពួកដ៏រំពង ហាក់ដូចសូរសំពួស្ករលាន់រំពងទៅដល់ឃ:ឆ្ងាយ
ទៅកុងវ:ហាស៍ទ្ធ ដ៏ល្ហូរល្ហូ ។ ព្រះសុបិនគំរប់ ៦ ថាមានបញ្ជាខ្ពស់
ឡើងទៅលើ, ខ្ពស់ឡើងជានិច្ច ១ លាលែតគេអាចមើលទៅឃើញសព្ព
ព្រះរាជធានី, មានកំពូលខ្ពស់ត្រជែតត្រជ ដ៏មជ្ឈមមួយ ហើយនៅលើ
បញ្ជានោះ មានព្រះរាជបុត្រស្ដេចគង់ទៅ, ទ្ងន់ព្ធ្ងសសាបពេញ ។
ព្រះហស្ដទៅសព្ធទិសានុទិស ហាក់ដូចជាព្រះពុ:ណាបុ:ជ្ជជាតនឹងតួ
ទ្ងន់ ហើយជនទាំងឡាយបៀតសៀតបៀ[illegible]គ្នា ដើម្ប:ស:ប្ដ:
យកទ្ធ:ព្ធ:ដ៏មានដ:ម្ដ:ដែលធ្លាក់ចុះមកគ្ដ:ប:ទ:ទ:ត:ប:ន ។ ហេតុគ:ទ:ក
គំរប់ ៧ ត:ជ:ានតួ:ស:ម:ក:ធ:ក:ដោយសំពួ:ស:ន:ងសៀ:ងយ:ស:ក ហើយទ្ងន់
ទ:ត:ឃើញ:ម:ន:ស:ស ១ ន:ក:ស្រ:ក:ទ:ហ:យ:ទ:ជ:ញ ១ យ:ក:ដ:ជ:ប:ទ:ម:ត:
ស:ក:ស:ត:ន:ត:ដោយ:ស:ចក្ដ:ម:ស:ន:ម ។

ន:ន:ត:ព្ធ:ន:ប:ទ:ទ:ង:ព:ប:ត:ម:ទ:ត:ស:ប:ស:ង:ដ:ល ព្ធ:ជ:ទ:ស:ន:ទ:-
ទ:ន:ទ្ងន់ ព្ធ:ន:ប:ទ:ម:ល:ឃើញ, ប:ន្ដ:ន:ន:ក:ហ:ក:ដ:ល ណ:ស:ក:ន:ដ:
ណ:ម:ម:ួ:យ ក:ច:ទ:ម:ព្ធ:ន:ប:ទ:ន:ន:ជ:ម:ន:ទ:ឡ:យ ហ:ត:ដ:ច:ន:
ហើយ ព្ធ:ក:ដ:ដ:ដ:ល:ទ:ង:ត:ស:ល:ត:ក:ម:ក:ន:ព្ធ:ទ:ម:ទ:ង:ន:ប:ន:ទ:ព្ធ:ន:ន:
ថ: "ត:ដ:ត:ន:ន:ន:ម:ន:ទ:ក:ខ:ម:ន:ម:ម:ក:ប:ន:ណ:ល:ដ:ល ព្ធ:ក:ក:ន:ប:ស:យ:ន:ដោ:ម
ពិ:ត:ហើ:ក:ន:ចំ:ណ:ម:ព:ក:ម:ន:ទ:ន:ន:ន:ន:ណ:ម:ម:ួ:ដ:ល:ម:ន:ចំ:ណ:ន:

ចេះដឹងធ្លាស់ធ្លាដួយតាមគ្រោះមើលឲ្យដឹងការណ៍ដែលព្រះធម្មាស់ដ៏ទ្រង់អានុភាពមកនិរមិត្តឲ្យប្រាកដដល់យើងដោយផ្លូវព្រះសុបិនទេនេះឡើយ" ដូច្នេះ ព្រះពុទ្ធជានី ទើបមានតែទុក្ខសោក ពីព្រោះព្រះពុទ្ធទ្រង់ព្រះសុបិនមិនល្អ រកនរណាមួយទាយថ្វាយគ្មាន តែវេលាគ្រានោះមានបុរសធ្លាក់ ស្លៀកពាក់ស្បែកសត្វដូចជាតាបសី គ្មាននរណាមួយដែលស្គាល់សោះ មកឈរនៅព្រះទ្វារហើយស្រែកឡើងថា "ចូរអ្នកនាំយើងទៅគាល់ព្រះពុទ្ធ, ព្រោះយើងអាចថ្វាយទំនាយ ព្រះសុបិនមិត្តនោះបាន" លុះតស៊ីនោះបានចូលទៅគាល់ ស្តាប់ព្រះឧត្តរៀងព្រះសុបិនទាំង ៧ ប្រការនោះហើយ ក៏បង្ហោនកាយចុះដោយសេចក្តីគោរពហើយគ្រាបទូលថា "ខ្ញុំ! ព្រះមហាពុទ្ធ, ទូលព្រះបង្គំសូមគោរពព្រះពុទ្ធតែកូល ដែលនឹងបានកត្ត្រាបសប់ផ្ទាត់សូស្ត្រសឹងមានស្ទីដ៏ប្រចិត្ត ត្រកាលកែលែងជាងជួងអាទិត្យ ! សូមឲ្យព្រះអង្គទ្រង់ធ្លាប់ចុះចាព្រះសុបិនដែលធ្វើឲ្យព្រះអង្គទ្រង់ខ្ជិតញ័ាបញ្ជ្រាវនេះ ជាព្រះសុបិនសុទ្ធតែជាមង្គលទាំងអស់, ដោយពិតនោះ ទង់ជ័យដែលបក់ប្រាប យ៉ាងរុងរឿងទង់នោះជាចំនាត់ហើយសោត់ធ្លាក់ចុះនោះ សំដៅដល់ការៈជាទីបំផុតនៃការធ្វើប្រការនូវទ្ធិចាស់ ហើយនឹងចាប់ផ្តើមកើតលទ្ធិថ្មី ព្រោះទេពតាទាំងឡាយមានមិនកែប្រែតំណាងមនុស្សលោកទេ, ឥឡូវជាច្រើនកប្ប ដែលកន្ទុងរំលងធ្ងន់មក ក៏មានទំនងដូចជាទ្រឹកដែលកន្ទុងផ្ទុតទៅ

ផែរ គជសារទាំង ១០ ធ្វើឲ្យផ្ទៃផែនដីញាប់ញ័រនោះ សំដៅដល់ព្រះមហាបារមីនៃធម្មវិសេសទាំង ១០ ប្រការ ដោយអំណាចព្រះធម្មវិសេសទាំង ១០ នេះ ព្រះពជ៉ររសេនឹងទ្រង់លះបង់ព្រះរាជធានីរបស់ព្រះអង្គហើយ នឹងទ្រង់ធ្វើឲ្យពិភពលោកញាប់ញ័រ ដោយការដឹកនាំលោកឲ្យបានលុះដល់ការបេះដឹងផលនៃសេចក្ដីទៀងទាត់, អស្សតរទាំង ៤ ដែលទឹមកដរថ ព្រួសធ្វើមចេញមកជាកើងនោះ គឺព្រះបុញ្ញាធិការដែលព្រះរាជបុត្របានសម្រេច គឺសង្ហៈទាំង ៤ ដែលនឹងនាំព្រះអង្គឲ្យបានឆ្លងផុតពីកន្ទានឹងការងងឹត ទៅកាន់ពន្លឺដ៏ស្វាងវែងនៃបុណ្យបារមី, កង់វិលជាសុវណ្ណប្រដាប់ដោយកែវចិន្ដាមណីនិងពេជ្រត្បូង ជាកង់វិសេសក្រៃលែង នៃព្រះវិន័យដ៏បរិសុទ្ធ ដែលនឹងវិលឲ្យប្រចក្ខច្បាស់ដល់លោកទាំងមូល, ស្អកដែលព្រះរាជបុត្រទ្រង់កាយធំ លានត្រឹកកង់ទៅគ្រប់ប្រទេសនោះ សំដៅដល់ការកង់រំពង់ដូចផ្គរគម្រាម នៃព្រះធម្មទេវ ដែលព្រះពជ់ចរសទ្រង់ទូន្មានប្រៀនប្រដៅ, បញ្ញាដ៏ខ្ពស់គ្រដែគទល់មេឃនោះប្រែថា ព្រះគម្ពីរដ៏វិសេសជាឯករបស់ព្រះពុទ្ធជាម្ចាស់, គ្រឿងត្បូងពេជ្រនិលចិន្ដាដែលបានសាចចុះមកអំពីបញ្ញានោះ គឺសម្បត្តិដ៏មានតម្លៃក្រៃលែងរបស់ព្រះធម្មវិន័យនេះ ដែលនាំគាប់ចិត្តរបស់ទេវតា និងមនុស្សទាំងឡាយ ហើយមនុស្សគ្រប់រូបសឹងត្រូវការចង់បានទាំងអស់,

(នៅមាន)

ប្រវត្តិព្រះមហារស់-គោ

អាចារ្យបង្រៀនសាលាបាលីរង វត្តកែវព្រះក្ងៃង សង្កាត់លេខ ៦

ក្រុងភ្នំពេញ

ភិក្ខុ ឡេវ ឈ្ឍរ

សំស្សម្ជាក់ឆ្នាំទី ១ ខែសាលាចាលីជាន់ខ្ពស់ រៀបរៀង

ព្រះមហា រស់-គោ បិតា នាម រស់ ផ្ទើពញា មាតា នាម ចិន លោកកើតពីថ្ងៃពុធ ១ កើតខែកត្តិក ឆ្នាំរកទោស័ក ព.ស.២៤៦២ ត.ស.១៩១៩ នៅភូមិគោកត្រាច ឃុំខ្នាត ស្រុកពួក ខែត្រសៀមរាប ។

កាលលោកនៅជាកុមារ អាយុ ៥ ឆ្នាំ បិតាអនិច្ចកម្មចោលទៅអាយុ ៨ ឆ្នាំ បានទៅសិក្សាអក្សរសាស្ត្រខ្មែរ នឹងលេខនព្វន្ត ក្នុងសំណាក់លោកគ្រូធម្មសត្ថាវិនំយធរ នាម (អ៊ិម-ធុយ) ចៅអធិការវត្តប្រាសាទ អាយុ ១០ ឆ្នាំ មាតាក៏អនិច្ចកម្មទៅទៀត អាយុ ១២ ឆ្នាំ ទៅនៅស្រុកពួក ក្នុងសំណាក់លោកគ្រូ (គង់) នឹងលោកគ្រូ (ឈ្មុប) ដើម្បីរៀនកុមារជ្ជានតទៅទៀត; ចូលអាយុ ១៣ ឆ្នាំ ក៏ត្រឡប់មកនៅ វត្តប្រាសាទវិញ ដល់ចុងអាយុ ១៣ ឆ្នាំ ដដែល បានលាលោកគ្រូព្រមទាំងបងប្អូនប្រុស-ស្រី ទៅនៅសិក្សាភាសាបាលី នៅទីសាលាបាលីរង វត្តដំណាក់ (សៀមរាប) ក្នុងសំណាក់អាចារ្យ (រស់-គុយ) ជាបង ។

អាយុ ១៥ ឆ្នាំ ត្រឡប់ទៅបព្វជ្ជា ជាសាមណេរ នៅវត្តជ្រោសាទ វិញ លុះបព្វជ្ជាហើយ ក៏ត្រឡប់មកកាន់វត្តជំណាក់ នៅបាន ២ ឆ្នាំ ក៏ចេញមកនៅវត្តលង្ការ សង្កាត់លេខ ១ ក្រុងភ្នំពេញ ក្នុងសំណាក់ លោកគ្រូអាចារ្យ "ប្រែស" បាន ១ ឆ្នាំ ក៏ត្រឡប់ទៅកាន់ខេត្ត សៀមរាប ដើម្បីប្រឡងយកទីណា "មហាបរិយត្តិបឋមវិជ្ជា" លុះ ប្រឡងជាប់រួចហើយ ក៏ត្រឡប់មកនៅភ្នំពេញវិញ ក្នុងថ្ងៃអាទិត្យ ១ កើត ខែអាសាធ ឆ្នាំធ្លុងនព្វស័ក ព.ស. ២៤៨០ គ.ស. ១៩៣៧ ឆ្នាំនោះ លោកគ្រូអាចារ្យ "ប្រែស" ក៏ចេញទៅនៅបាត់ដំបងទៅ! ។

សាមណេរ រស់-ភា ក៏ចេញទៅសូមនៅវត្តកែវព្រះភ្ជ័ង (ភ្នំពេញ) បានប្រឡងចូលរៀននៅសាលាបាលីជាន់ខ្ពស់, លុះបានរៀនផុត ១ ថ្នាក់ ក៏វិលទៅកាន់ស្រុកកំណើតវិញ ដើម្បីបំពេញឧបសម្បទា ជាភិក្ខុភាព ក្នុងថ្ងៃសុក្រ ៥ កើតខែធណ្ឌនឆ្នាំចោះឯកស័ក ព.ស. ២៤៨២ គ.ស ១៩៣៩ ក្នុងព័ទ្ធសីមា វត្តជ្រោសាទ ឃុំឆ្នាត ស្រុកពួក ខេត្តសៀមរាប ដរាបណា; លោកគ្រូធម្មសត្ថាវិនិយធរ នាម "ឆុយ" ជាឧបជ្ឈាយ៍, លោក គ្រូព្រហ្មជោត នាម "យក" ជាកម្មវាចា, លោកគ្រូធម្មជោត នាម "សិទ្ធ" ជាអនុសាវ័ន: ឧបជ្ឈាយ៍ឲ្យនាមបញ្ញត្តិជាភេទ្ទ: ។

លុះបានឧបសម្បទារួចហើយ, ភិក្ខុ រស់-ភា ក៏ត្រឡប់មកកាន់វត្ត កែវព្រះភ្ជ័ងវិញ ក្នុង ព.ស. ២៤៨៥ គ.ស ១៩៤២ ចូលរៀននៅ

សាលាបាលីជាន់ខ្ពស់ត្រប់ ៤ ឆ្នាំហើយ ក៏ចេញមកធ្វើជាអាចារ្យបង្ហាត់ប្រៀនទៅសាលាបាលីវត្តកែវ ព្រះភ្លើងដែល ។

លោកអាចារ្យអង្គនេះ ជាអ្នកយកចិត្តទុកដាក់ក្នុងការបង្ហាត់ប្រៀនដោយផ្ទាល់ខ្លួនតតាមខ្លាចទៀយ ព្រួយទ្បើយ ដើម្បីទ្រទ្រង់ការសាសនា, ខាតុកូមិ ដែលជាទីស្រឡាញ់របស់លោក ឲ្យបានទៅជាអាត្មាជាតិក្នុងលោក; ហើយតាំងទៅក្នុងហ្ជ:ជាធម្មកថិកយ៉ាងឯក សំដែងធម៌ទេសនាប្រដៅ ប្រជាជន ត្រប់ទីដំបន់ ទ្ធ:ជនបទនានា ក្នុងដែនកម្ពុជាយើងនេះ ។ អ្នកធ្ងន់ បានស្តាប់ធម៌អាចំពាក្យសំដីចូ:ចិត្តរបស់លោក ហើយតែងមានសេចក្ដីស្ងើចសរសើរស្ងើរតែកាលមាត់ ។ ទៅ:ពេលចំនួ:ខ្ទ:ះ លោកបានទ្ធ:ត្រៀតរៀបរៀងក្ជ:ន្ធ:ចាប់ ទុកសម្រាប់កុលបុត្រសិក្សារៀនសូ:ត្ជ:ជ:ច្រើន ដូចរៀបកាប់ខ្ទ:ះ ត:ទៅ ។

១ - ភូមិសាស្ត្រសង្ខេបនៃមហាចូ:ត្ជ:ចូ:ប, ២ - វិធីសាងសំ:ឡ:ង' ៣ - ការសិក្សាប្រកបដោយអង្គ ៣, ៤ - សាមគ្គីកថាជាដើម ។

ឯសៀវ:ត:ទៅក្ជ:ន្ធ:ចាប់ទាំងនេះ សុទ្ធតែជាស្នាព្រះហស្តរបស់លោកទាំងអស់ ជាបណ្ដាលលោកមានកាពាន ធ្ងាក់ណាមជាទ្ធ:ម្ជ:ម ជិត ១ ឆ្នាំ ។

លោកអនិ:ច្ជ:ធម្ម:ទៅថ្ងៃ:ចន្ធ:ជ:ប់ពេ:ចវ:ចៃ:ត្រ:ត្ជ:ន្ធ:ាំ:ជ:ត សំ:ទ្ធ:ិ:ស:ក ព.ស. ២៤៩១ ថ្ងៃ ៣ ខែ ១ សកា ឆ្នាំ ១៩៤៨ ដោយពេ:ត:ជ:ចាងលើ ក្ជ:ន្ធ:ាយុ:ត:ប ២៩ ឆ្នាំ ។

ពួកសិស្សានុសិស្ស ទាំងពួកញាតិមិត្រព្រមទាំងឧបាសក ឧបា-សិកា បានដំកល់សពលោកទុកអស់កំឡុង ៣ ថ្ងៃ នៅទីសាលាបាលីរងវត្តកែវព្រះភ្លើងដែលរចនាតាក់តែងដោយគ្រឿងសក្ការៈដ៏ថ្ងៃថ្លា ដើម្បីធ្វើទក្ខិណានុប្បទាន ឧទ្ទិសបុណ្យកុសលប្រគេនលោក គឺ យប់ចំរើនព្រះបរិត្ត - ទេសនា ព្រឹកឡើងវេរភត្តប្រគេនសង្ឃជានិច្ច ៗ ដល់ថ្ងៃអាទិត្យ ២ កើតខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ ត្រូវនឹងថ្ងៃ ៩ ខែឧសភា គ.ស. ១៩៤៨ វេលាម៉ោង ១៥ រសៀលជួបជុំពួកពុទ្ធបរិស័ទ រំកិលសពចេញពីសាលាបាលីរង ទៅដំកល់លើរថយន្ត រៀបក្បួនហែ មានលោកសង្ឃសិស្សានុសិស្ស ទាំងនិស្សិត នៃសាលាគរុវិជ្ជា ព្រមទាំងពួកឧបាសក ឧបាសិកាជាច្រើន ដង្ហែតាម រីឯកញ្ញាអ៊ុំ - សុទ្ធាវង្ស (ឈប់បង្សុកូលនៅទីសាលាបាលីជាន់ខ្ពស់) រីឯកញ្ញា ឈុន - ខុងារដីឡាត្រ (ឈប់បង្សុកូលនៅមុខសាលាគរុវិជ្ជា) រីឯព្រៃនគរ នៅតាមចំពោមថ្នល់ មានឧបាសក - ឧបាសិកាត្រៀបត្រាមានគ្រឿងសក្ការៈនៅដៃ រង់ចាំហែសពលោក ដែលសំដែងទឹកមុខជប់ស្រពោនយ៉ាងស្ងប់ស្ងៀម គួរឲ្យកើតធម្មសង្វេគ (ឈប់បង្សុកូលនៅក្រោយវត្តប្រយុរវង្ស-នួនមណីរាម) បតតាមរីឯកញ្ញា អ៊ុំ ចូលមកកាន់វត្តកែវព្រះភ្លើងវិញ រំកិលសពចាករថយន្ត ទៅដាក់ដំកល់លើបារាំសម្រាប់បូជា ដែលរៀបតាក់តែងដោយភ័ក្កា យ៉ាងពិចិត្រ ។

នៅបាវាំសម្រាប់ទទួលក្ស្រៀ ព្រះតេជព្រះគុណ សម្តេចព្រះធម្ម-
លិទិត (ល្ងី-ឯម) ចៅអធិការវត្តលង្ការ; ព្រះតេជព្រះគុណ ព្រះវនរ័ត៍
(ម្រឿង) វត្តឧណ្ណាលោម, ព្រះតេជព្រះគុណ ព្រះទេពសត្ត
(សូរ-ហាយ) វត្តឧណ្ណាលោម, ព្រះតេជព្រះគុណ ព្រះមហា (ប៉ាង-
ទាត់) វត្តឧណ្ណាលោមជាដើម ព្រមទាំងតស្សរជនឯទៀតជាច្រើន បាន
និមន្ត នឹងអញ្ជើញមកជាអធិបតីបុណ្យ ។ មោង ១៧ រៀបបូជា មុននឹង
បូជា លោក (គង់) ទីប្រឹក្សាព្រះរាជាណាចក្រ បានសូត្រប្រវត្តិរបស់
លោកនឹងសុន្ទរកថាលុះចប់ សម្តេចព្រះធម្មលិទិតប្រទានក្ងើង ។ ព្រឹក
ឡើងថ្ងៃច័ន្ទ រវរកត្តប្រគេនសង្ឆ មោ៉ង ៦០ និមន្តធម្មកថិកពីរអង្គសំដែង
ធម៌ បុច្ឆា-វិស្សជ្ជនា ផ្សាយតាមវិទ្យុគ្សោសនស័ព្ទ ជាកិច្ចធ្ងងបុណ្យ
តែប៉ុណ្ណោះ ។

បុណ្យមួជាសពអ្នកអាចារ្យ ហ៊ុន សុជ

ភិក្ខុ សួន - សុវិន្ទ រវិវង្សា

(ពមក)

ក្សួនហែសពវេលាយប់

សង្ការត់ទី ១ – ពួកអ្នកកាន់គប់ក្រូង	សង្ការត់ទី ៣ – រថយន្តដំកល់សព
– ២ – ភិក្ខុសាមណេរ ១៥០	– ៤ – ក្រុមស្ត្រីដើរហែ
រូបចំរើនមរណស្សតិ	– ៥ – ក្រុមបុរសដើរហែ

លុះហែទៅដល់វត្តពិពិធហើយ មានអុជកាំជ្មួចភ្ជីទ្រៀន - សម្រែកសត្វទទួលសពជាកិត្តិយស ហើយនិមន្តធម្មកថិក ១ រូបសំដែងធម៌ទេសនាលុះចប់និមន្តព្រះសង្ឆ ៨ រូបសូត្រព្រះអភិធម្ម ។

៤– ថ្ងៃ ៥ កើត ត្រង់នឹងថ្ងៃទី ៣-៤-៤៩ វេលាព្រឹកប្រគេនយាគូ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌចាតដល់ព្រះសង្ឆនៅវត្តពិពិធ ៥០ រូប នៅវត្តពោធ៏វាល ២០០ រូប វេលាម៉ោង ១៥ រំកិលសពទៅដំកល់លើរូបរាជ-សីហ៍ ដែលរចនាដោយស្វឹកឈើស្រស់ជារបស់ចំទ្បែកគួរឲ្យទស្សនាការហែសពត្រឡប់មកវត្តពោធ៏វាលវិញ ។

ក្សួនហែសពវេលាថ្ងៃ

សង្ការត់ទី ១ – ក្រូងពំណាពាទ្យ អ្នកចាត់រៀប នាយឈុប-

សង្ហាត់ទី ២ - បុស្សបុកដំកល់ព្រះពុទ្ធរូបបរិនិព្វាន អ្នកចាត់. នាយសារុន

- ៣ - សម្ពេចព្រះសង្ឆនាយកទាំង ២ គណ : អភិធម្ម - ស្ងឿក

- ៤ - លោកគ្រូអនុគណ ទាំង ៨ មាតិកា - រន្ទា

- ៥ - ភិក្ខុសាមណេរ ២០០ រូបចំរើនមរណស្សតិ ឡុត

- ៦ - សង្ឆឹកដាក់គ្រឿងបរិក្ខារប្រគេនសង្ឆ - ស្រគំ

- ៧ - ក្រុមភ្ជងត្រែវង់ - ប្ទ្ធិ

- ៨ - ក្រុមអាចារ្យយោគីកាន់ទង់ ៨ - ស៊ុនលី

- ៩ - ក្រុមអ្នកកាន់ផ្ការកម្រង - យឿម

- ១០ - អ្នកកាន់ទង់ស្ឆង់សរសេរធម្ងសង្ឆេត - គ្រូសំអាត

- ១១ - អ្នកកាន់ទង់សំពត់សសរសេរធម្ងសង្ឆេត - គ្រូឈឿម

- ១២ - អ្នកកាន់ទង់សំពត់ឡេសរសេរធម្ងសង្ឆេត - គ្រកូយ

- ១៣ - ក្រុមភ្ជងក្ងងទៃក - នាយអ៊ាន

- ១៤ - ឧបាសកកាន់ត្រៃ - ឈឿម

- ១៥ - រាជសីហ៍ដំកល់សព - ស៊ុយហេង

- ១៦ - ក្រុមអ្នករាជការដើរហ - សុវណ្ណ

- ១៧ - ក្រុមបុរសដើរហ - សំផៅ

- ១៨ - ក្រុមស្ត្រីដើរហ - នាយហុក

ទង់ស្ឆង់ - សំពត់ស - សំពត់ឡេ ទាំងអស់សុទ្ធតែសរសេរធម្ងសង្ឆេត

មានសរសេរថា "រូបំ អនិច្ចំ ទុក្ខំ អនត្តា" ដូច្នេះជាដើម ។

ក្បួនហែនេះមានចាត់អធិបតីជា ២ ផ្នែកគឺ អធិបតីខាងលោកសង្ឃ ១ ផ្នែក ខាងឧបាសក ១ ផ្នែក ។

អធិបតីខាងលោកសង្ឃ

១ — ព្រះមហាព៉ត អធិបតី

២ — ភិក្ខុ សួន-យ៉ន និងភិក្ខុ សួន-សុរិន្ទ រងអធិបតី

អធិបតីខាងឧបាសក

១ — អ្នកអាចារ្យ អ៊ុច អធិបតី

២ — ហ៊ាប៊ុន-កាក់ និងហ៊ាប៊ុន រងអធិបតី ។

អ្នកចាត់របៀបទាំងអស់ សុទ្ធតែកាន់ទង់ស ១ ខ្មៅ ១ គូចៗ គ្រប់គ្នា ទង់សបកស្រញ្ញាថា "ទៅ" ទង់ខ្មៅបកស្រញ្ញាថា "ឈប់" ។ ក្បួនហែមានរបៀបរៀបរយល្អ មនុស្សហែរាប់ពាន់នាក់ ស្ងាត់មាត់ឈឹងរំពឹងមរណស្សតិគ្រប់ៗគ្នា ក្បួនហែចេញពីមុខវត្តពិពិធព័ទ្ធផ្សារ ចេញមកវិថីនរោត្តមឆ្លងស្ពានថ្ម ម្រង់ចូលទៅវត្តពោធិ៍វាល លុះដល់ហើយលើកហែមទៅដាក់លើគ្រឿងជាន់ក្នុងបារាំយ៉ាតវត្តពោធិ៍វាល ស៊ីងមានព្រះមហាគន្ធ សុខេត ជាអធិបតីក្នុងវិធារណកិច្ចនេះ ។

វេលាលើកសពដាក់លើគ្រឿងជាន់ស្រេច អស់លោកមន្ត្រីខ្មែរ បារាំង យកផ្កាម្រងទៅគំនាប់សព ហើយមានវិធីចែកទានដល់ក្រុមអ្នក

ជំនួយនឹងលៀងគោជនាហារមន្ត្រីខ្មែរ-ចាកាង ។ ពេលម៉ោង ១៩ ទិមន្ត ព្រះសង្ឆចំរើនព្រះបរិត្ត ធ្វើកិច្ចពុទ្ធាភិសេក ម៉ោង ២១ ទិមន្ត ព្រះតេជ-គុណ ព្រះមហា សុមេធាធិបតីសង្ឆនាយកគណមហានិកាយសំដែងធម្ម-ទេសនា លុះចប់ទើបព្រះតេជ-គុណ ព្រះមុនីកោសលថ្លែងប្រវត្តិអ្នកអា-ចារ្យហ៊ុន-សុជ ដូចមានសេចក្ដីបរិយាយតទៅខាងមុខនេះ ។

ប្រវត្តិអ្នកអាចារ្យហ៊ុន – សុជ ទ្រង់សេចក្ដីថ្លែងអាណ្ណាយ

ព្រះតេជគុណ ព្រះមុនីកោសលមេគណ ខេត្ត ត្រាត់ដ៏ចង ថ្ងៃ ២ ចំណោះពួកពុទ្ធបរិស័ទ

សូមទ្ទួលពុទ្ធដីកា ព្រះថេរានុត្ថេរៈ ទាំងឡាយ !

សូមជំរាបលោកអ្នកសប្បុរសទាំងអស់ !

ឧកាសនេះ ខ្ញុំ ព្រះគុណ អាត្មាភាព សូមថ្លែងប្រវត្តិអ្នកអាចារ្ય សុជ លើកយកគុណធម្មដែលគាត់ធ្លាប់ធ្វើហើយក្នុងវត្តនេះ ឲ្យលោកអ្នកទាំងឡាយបានជ្រាបថា មនុស្សម្នាក់នេះធ្លាក់ទ្ធាំងដៃធ្ងៃនឹងដៃស្ដាំ របស់ខ្ញុំ ព្រះគុណ អាត្មាភាព គួរនឹងសំដែងកិត្តិគុណ ឲ្យសមនឹងបំណាច់ ដែលគាត់ធ្លាប់ធ្វើរួចមកហើយ មានសេចក្ដីដូចតទៅនេះ

ជាតិភូមិ

អ្នកអាចារ្យ សុជ បិតាឈ្មោះ ហ៊ុន មាតាឈ្មោះ គ្ម កើតនៅភូមិមុ ១ វត្ត ពោធ៍ ឃុំ សង្ដ ខេត្ត ចាត់ដ៏ចង ក្នុងថ្ងៃ អង្គារ ១៤ រោច ខែ អស្សុជ

ឆ្នាំកុរឯកស័ក ព.ស ២៤២២ វេលាម៉ោង ៥ កន្ទុះអរុណដិតរះ មានបងប្អូន ២ នាក់ ទី ១ ជ្រៃតាក ទី ២ អ្នកអាចារ្យ សុជ

ការសិក្សា

កាលកុមារ សុជ មានអាយុ ៥ ឆ្នាំ បិតាបានឲ្យសិក្សាអក្សរសម្រាប់ជាតិ ចេះសរសេរ - អានបាន ដល់អាយុ ១៣ ឆ្នាំមាតាបិតាបាននាំមកផ្ញើនឹងព្រះគ្រូ កម្ពុជរតនវង្ស (សន) វត្តពោធិ៍រាល ។ លុះរៀនលេខនឹងធម៌ចេះហើយ មាតាបិតាបានធ្វើមង្គលកាត់ផុក ហើយបំបួសជាសាមណេរ ព្រះគ្រូកម្ពុជរតនវង្ស៍ជាព្រះឧបជ្ឈាយ៍ ។ លុះបួសរួចហើយ សាមណេរសុជ រៀនព្រះវិន័យបិដកក្នុងសំណាក់ ព្រះគ្រូកម្ពុជរតនវង្ស៍ បួសបាន ៣ វស្សា លោកគ្រូអនិច្ចធម្ម ទើបចេញទៅរៀននឹងលោកគ្រូអាចារ្យឈិន លោកគ្រូអាចារ្យ ទុកវត្តសង្ខ រៀននឹងលោកគ្រូមហាកាជ លោកគ្រូមហាកូនៅវត្តកណ្ណាល ។ ដល់អាយុ ១៧ ឆ្នាំ បួសបាន ៥ វស្សា ចានចូលទៅសិក្សានឹងលោកគ្រូមហាប៉ាន់ វត្តចក្រវត្តិ-ពជ្ជាវាស ក្រុងបាត់ដក លុះអាយុគ្រប់ ២០ ឆ្នាំ ក៏ចូលឧបសម្ប៉ាទនិមន្ត ព្រះមង្គលទិព្ធមុនីជាព្រះឧបជ្ឈាយ៍ និមន្ត ព្រះមហាប៉ាន់ ព្រះគ្រូចាន ឡាត់តាន ជាកម្មវាចា ក្នុងព័ទ្ធសីមាវត្តចក្រវត្តិ បួសបាន ១ វស្សា ក៏ចូលមកនៅវិទ្យាគ្រប ប្ដាត់ដំបងវិញ ។

សមណសក្តិ

បួសបាន ៥ វស្សា អាយុ ២៥ ឆ្នាំ ធ្វើជាគ្រូសូត្រ ជំនួយចៅអធិការ ដល់អាយុ ៣២ ឆ្នាំ រាជការបានតាំងជាគ្រូបង្រៀនសាលាបាលីវត្តពោធិ៍-ពល អាយុ ៤២ ឆ្នាំ វស្សា ២២ បានទទួលនាទីជាព្រះគ្រូធម្មវិសុទ្ធិ ។

ការបរិហារ

កិច្ចការទាំងឡាយក្នុងវត្ត បើចៅអធិការរៀបចំដូចម្តេចក៏ជួយជាកំឡាំងស្មើគ្នាឥតមើលបំណាំ ឧស្សាហ៍ដឹកនាំប្រៀនប្រដៅភិក្ខុសាមណេរឲ្យមានកិរិយាមារយាទរៀបរយសមគួរជាសមណៈ នឹងជួយតែងសេចក្តីបញ្ញត្តិផ្សេងៗសំរាប់វត្ត ឲ្យមានរបៀបរៀបរយទាំងភិក្ខុសាមណេរ ឧបាសក ឧបាសិកា ។ កិច្ចការទាំងឡាយបើចាប់ធ្វើហើយ ទោះមានឧបសគ្គមកខ្លាំងខ្លួប់ក៏ខំប្រឹងដោយសេចក្តីព្យាយាមដរាបដល់បានសំរេច ។

ការបង្ហាញគន្ថធុរៈនឹងវិបស្សនាធុរៈ តាំងអំពីត្រឡប់ពីស្រុកសៀមមក ក៏ខំប្រឹងបង្ហាត់បង្ហាញធម្មវិន័យដល់ភិក្ខុសាមណេរពេលថ្ងៃឥតមានធុញទ្រាន់ បានឃើញអ្នករៀននឹងគ្រូកម្មដ្ឋានឃ្មៀងឃ្មាតអំពីពុទ្ធវចនៈ មានសេចក្តីស្មុតចិត្ត ខំសិក្សាក្នុងវិបស្សនាធុរៈយល់សព្វគ្រប់ ទើបតាំងបង្ហាត់បង្ហាញព្រះកម្មដ្ឋានដល់ ឧបាសក-សិកា មានកេរ្តិ៍ឈ្មោះដរាបដល់មានភិក្ខុសាមណេរ ឧបាសក-សិកាចូលខែត្រមករៀនជាច្រើន ។

ការបដិសង្ខរណៈព្រះអារាម

ព្រះតេជ - គុណ !

លោកអ្នកសប្បុរសទាំងឡាយ !

វត្តពោធិ៍ជ្ជលក្ខន្ធសម័យពុទ្ធសករាជ ២៤៦០ វិហារ-ក្ដី-សាលាធម្ម-មន្ទីរទុព្វលភាពខ្វាំង ខ្ញុំព្រះករុណាអាត្មាភាពក្ដី អ្នកអាចារ្យសុជក្ដី ឥតមានទំនេរ ទំប្រឹងប្រែងជួសជុលទ្រឹងកសាងជារាបមក ព្រឿងបុរាណវត្ត គឺអ្នកអាចារ្យសុជជាអ្នកផ្ដើមគិត ដើម្បីរក្សាបុរាណវត្តកុងវ៉ែតនេះឲ្យគង់នៅ ខ្ញុំព្រះករុណាអាត្មាភាពក៏ទំប្រឹងជួយចាត់ការឲ្យបានសំរេចដូចប្រាថ្នាស្នាដៃដែលអ្នកអាចារ្យសុជកសាងចំពោះខ្លួន ដោយខ្ញុំព្រះករុណាអាត្មាភាពឥតបានជួយនោះគឺ: វិបស្សនាមន្ទីរទ្រឹងក្ដុងដែលប្រតិស្ឋានព្រះពុទ្ធរូបទុក្ករកិរិយា

ជីវិតអវសាន

អ្នកអាចារ្យសុជមានអធ្យាស្រ័យម្យ៉ាងគឺ: ខ្លួនដូចម្ដេច ចង់ឲ្យសិស្សប្រព្រឹត្តដូចខ្លួន និស្ស័យធ្ងន់ទ្រឹងអស់ មកអំពីសេចក្ដីធ្ងន់ចិត្តព្រឿងសិស្សប្រជៀត កើតសេចក្ដីអផ្សុកចាកសំគ្នាបង. ថ្ងៃ ១៣ កើតខែបុស្ស ឆ្នាំម្សាញ់ ព. ស. ២៤៨៤ ប្រកបកិច្ចការរកទ្រព្យ ទានដោយសេចក្ដីព្យាយាមមកដល់ថ្ងៃ ១០ កើត ខែអាសាធ ឆ្នាំមមី ក្រុមញាតិបានចាត់ធ្វើវិវាហមង្គលនឹងបែងដាប ចានប្រកបកិច្ចការរកទ្រព្យ ទានចំរើនដោយទ្រព្យសម្ផត្ដិល្ហមសមគ្ដួរដល់ហាន: លុះដល់មកថ្ងៃ ១៥ កើត ខែមាឃ ព. ស.

២៤៨៧ ចាប់ផ្ដើមដោយរោគគ្រុនបាន៣ថ្ងៃ បានអញ្ជើញពេទ្យមកពិនិត្យ
មើលថារោគកណ្ឋៈ (អុតធំ) ភរិយាព្រមទាំងសិស្សានុសិស្សនឹងញាតិ
មិត្តទាំងប្រុសស្រីរកគ្រូជាច្រើនមកព្យាបាលអាការៈរោគ មានកំឡាំងផុត
និស្ស័យហួសពេទ្យនឹងរក្សាបាន ។ សូម្បីទាហានយ៉ាងឯកនៃស្ដេចមច្ចុចូល
មកញាំញីរាងកាយឲ្យបានទទួលទុក្ខវេទនាជាទម្ងន់ដល់ម្ល៉េះ ភរិយាអ្នក
អាចារ្យសុជស្ងប់ស្ងៀមតតមានញាប់ញ័រ មិនដែលថ្ងូរពោលពាក្យអ្វីឲ្យ
ញាតិមិត្តសង្កេតបាន សិស្សខ្លះនឹកសង្ស័យសួរថាៈ លោកគ្រូ ! យើងខ្ញុំ
មើលឃើញរាងកាយលោកគ្រូគួរឲ្យទុក្ខវេទនាខ្លាំងណាស់ ប៉ុន្តែលោកគ្រូ
ព្រងើយប្រហែលជាខាងក្នុងមធ្យមទេ ឬ ? អ្នកអាចារ្យតបថា តាមទុក្ខ-
វេទនាឥតមានអ្វីនឹងប្រៀប រាងកាយទាំងមូលគ្មានសាច់ត្រង់ណាដែល
បន្ទោះមិនឈឺនោះគ្មានសោះ ដែលអត់ធន់បាន មកអំពីខ្ញុំធ្លាប់គិតធ្លាប់
ហ្វឹកហ្វឺនចិត្តមក ។ លុះដល់ថ្ងៃ ៩ កើតដឹងខ្លួនថាៈ ជីវិតនឹងទ្រទ្រង់
នៅមិនបាន ទើបនិមន្តខ្ញុំព្រះករុណាអាត្មាភាពចូលទៅជិត ហៅភរិយា
មកអង្គុយជិតខាងហើយប្រាប់ថាៈ ខ្ញុំព្រះករុណាធ្លាប់គិតមករឿយៗចំពោះ
អនិច្ចតាធម៌នេះ គ្រឿងប្រើប្រាស់ដែលខ្ញុំធ្វើច្រើនតាំងចិត្តថាៈ កើតមក
មួយជាតិឲ្យមានគ្រឿងប្រើប្រាស់គ្រប់គ្រាន់ប៉ុណ្ណោះ ភរិយាខ្ញុំព្រះករុ-
ណាឃាត់មិនឲ្យធ្វើ ព្រោះគ្មានកូននឹងទទួលមត៌ក ខ្ញុំព្រះករុណាថាៈ
គ្មានកូនស្លាប់ទៅយើងយកទៅផង ទើបភរិយាខ្ញុំព្រះករុណាព្រមឲ្យធ្វើ
និយាយតែប៉ុណ្ណោះឈប់មួយស្របក់ ទើបបែរទៅសួរភរិយាថា ថែឲ្យអ្វីខ្ញុំ

ខ្លះ? ភរិយាតបថា របស់ណាដែលមានហើយ លោកគ្រូត្រូវការអ្វីខ្ញុំជូនទាំងអស់ របស់ណាដែលមិនទាន់មាន លោកគ្រូត្រូវការអ្វីខ្ញុំចាត់ការជូនទាំងអស់តាមត្រូវការ សូមលោកគ្រូកុំក្រែងចិត្តឡើយ អ្នកអាចារ្យទទួលថា សាធុ! ហើយប្រាប់ថា ខ្ញុំធ្វើគ្រឿងបូជាដោយប្រាក់មិនទាន់គ្រប់ សូមតែចាត់ធ្វើឲ្យគ្រប់តាមបំណងខ្ញុំចុះ លុះរាត្រីថ្ងៃ ១១ កើតនិមន្តឲ្យទៅជិតហើយប្រាប់ថា: យប់នេះខ្ញុំព្រះករុណា សូមឲ្យស្លាប់ ខ្ញុំព្រះករុណា អាត្មាភាពក៏ដឹងបានថា អ្នកអាចារ្យនឹងលះលោកនេះទៅក្នុងរាត្រីនេះក៏សំរួលតាមអធ្យាស្រ័យ ។

គួរអស្ចារ្យណាស់ ព្រោះទីធ្យារវេលាទៀបព្រឹក អ្នករកទទួលទានតែងក្រោកឡើងធ្វើការងារ រទេះសេះឬរទេះឡានក៏តែងបើកបរ រាត្រីដែលអាចារ្យសូមឲ្យស្លាប់ ជាអានិសង្សដែលអ្នកអាចារ្យធ្លាប់អប់រំមក ទើបរាត្រីនោះក៏ស្លាប់ រហូតដល់ពេលដែលអ្នកអាចារ្យអស់ត្រូវការតអំពីសូមស្លាប់មក អ្នកអាចារ្យក៏ស្ងប់ស្ងៀមទទួនស្តាប់ខ្យល់អស្សាសៈបស្សាសៈ ព្រុកស្រួល "អរហំ" រាល់ដង្ហើមចេញចូល លុះវេលាម៉ោង ៥ កន្លះ អ្នកអាចារ្យក៏លះលោកនេះទៅកាន់លោកខាងមុខដោយសេចក្ដីស្ងប់ ក្នុងថ្ងៃ អង្គារ ១១ កើតខែមាឃ ឆ្នាំរកាសប្តស័ក ព.ស. ២៤៨៧ ត្រង់នឹងថ្ងៃ-វេលាដែលអ្នកអាចារ្យកើត ហេតុដែលអ្នកអាចារ្យធ្វើមរណកាលដោយមានសតិសម្បជញ្ញៈនេះ ជាភស្តុតាងមួយដ៏សមរម្យតាមឋានៈជាអ្នករៀនជាអ្នកប្រដៅព្រះកម្មដ្ឋានដោយពិត ។ (មាឌក)

អំពីតាំងថៅអធិការ

(ពមក)

សញ្ញាប័ត្រលេខ ២១៥ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ យ៉ង់-នៅ នាមធាយា ធម្មត្ថេរបញ្ញា កើតឆ្នាំខាល អាយុ ៣៥ វស្សា ២ ជាគ្រូសូត្រស្តាំ វត្តគិរី ឃុំធៃប ស្រុកធៃប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២១៦ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ភិម-ស៊ុំ នាមធាយា ធម្មសត្ថា កើតឆ្នាំជូត អាយុ ២៥ វស្សា ២ ជាគ្រូ សូត្រធ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២១៧ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ធួន-អ៊ុល នាមធាយា ធម្មញ្ញាណ កើតឆ្នាំជូត អាយុ ២៥ វស្សា ២ ជា ថៅអធិការវត្តទេពនិមិត្ត ឃុំមូ ស្រុកធៃប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២១៨ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ ថោង-ណាក់ នាមធាយា ធម្មិស្សរ: កើតឆ្នាំថោះ អាយុ ២៦ វស្សា ២ ជា គ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២១៩ ចុះកាលបរិច្ឆេទដែល តាំងលោកគ្រូ អៀ-តុល នាមធាយា ធម្មជោត កើតឆ្នាំធ្ងូរ អាយុ ២៦ វស្សា ២ ជាគ្រូ សូត្រធ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-យឹម សុវណ្ណប្បញ្ញោ កើតឆ្នាំឆ្លូរ អាយុ ២៤ រស្យា ៤ ជាចៅអធិការ វត្តគិរីវន ឃុំចាច់ ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពៃ-ចិន នាមធាយា ធម្មត្ថេរ កើតឆ្នាំកុរ អាយុ ២៦ រស្យា ៤ ជាគ្រូសូត្រ ស្តាំនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន-សុខ នាមធាយា ធម្មសុវណ្ណ កើតឆ្នាំម្សាញ់ អាយុ ២០ រស្យា ១ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពុត-សម នាមធាយា ធម្មសត្ថា កើតឆ្នាំរោង អាយុ ២១ រស្យា ១ ជា ចៅអធិការវត្តសំពៅកែវនិមិត្ត ឃុំពើក ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-អៀង នាមធាយា ធម្មប្បញ្ញោ កើតឆ្នាំរោង អាយុ ២១ រស្យា ១ ជា គ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គុច-សៃ នាមធាយា ធម្មជោត កើតឆ្នាំរោង អាយុ ២១ រស្យា ១ ជាគ្រូ សូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អែម - ហែម នាមធាយា ចន្ធត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១ ជា ចៅអធិការវត្តគគីរ ឃុំអំពិល ស្រុកមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ូញ - ប៊ុត នាមធាយា ធម្មកេស្សរ: កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្រដដែល ។

សញ្ញាប័ត្រលេខ ២៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ឹក - តន់ នាមធាយា ចិត្តត្ថេរ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជា ចៅអធិការវត្តពោធ៌ទង ឃុំកញ្ជៀច ស្រុកកញ្ជៀច ខេត្រត្រៃព្រវែង ។

សញ្ញាប័ត្រលេខ ៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ - ឡុង នាមធាយា យសត្ថេរ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៤ ជា ចៅអធិការ វត្តត្រពាំងថ្ថាន់ ឃុំព្រាល ស្រុកកញ្ជៀច ខេត្រត្រៃព្រវែង ។

សញ្ញាប័ត្រលេខ ៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម - គង់ នាមធាយា គិតត្ថេរ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣៣ ជា ចៅអធិការវត្តក្រឡាមាយ ឃុំត្នោត ស្រុកកញ្ជៀច ខេត្រត្រៃព្រវែង ។

សញ្ញាប័ត្រលេខ ២៣.៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លុក - ម៉ោង នាមធាយា ធម្មត្ថេរ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៥ ជាចៅអធិការវត្តត្នោត ឃុំត្នោត ស្រុកកញ្ជៀច ខេត្រត្រៃព្រវែង ។

សញ្ញាបត្រលេខ ២៣៤ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ពេជ - គង់ នាមធាយា ឥន្ទកេសរ កើតឆ្នាំថោះ អាយុ ៧០ វស្សា ៤៩ ជាចៅអធិការវត្តពោធ៍ខ្ទាវ ឃុំព្រាល ស្រុកកញ្ជ្រាច ខេត្រត្រៃត្រវង ។

សញ្ញាបត្រលេខ ២៣៥ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ គុយ - គង់ នាមធាយា ធម្មត្ទេរ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាចៅអធិការវត្តពង្រ ឃុំគោកគង ស្រុកកញ្ជ្រាច ខេត្រត្រៃត្រវង ។

សញ្ញាបត្រលេខ ២៣៦ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ សុខ - សេង នាមធាយា គម្ភីរបញ្ញា កើតឆ្នាំមមី អាយុ ៣១ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តព្រះស្រែ ឃុំ - ស្រុកកញ្ជ្រាច ខេត្រត្រៃត្រវង ។

សញ្ញាបត្រលេខ ២៣៧ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ធាង - ជួប នាមធាយា សារប្បញ្ញា កើតឆ្នាំមមី អាយុ ៣១ វស្សា ៦ ជាគ្រូសូត្រធ្វេង នៅវត្ត ឃុំ - ស្រុក - ខេត្រដដែល ។

សញ្ញាបត្រលេខ ២៣៨ ចុះថ្ងៃអង្គារដប់មួយរោចខែស្រាពណ៍ ឆ្នាំ ជូតសំរិទ្ធិស័ក តាំងលោកគ្រូ សិង - ផុន នាមធាយា ឥន្ទសត្ទា កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការវត្តពោធ៍ព្រះបាទ (ច្បារអំពៅ) ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្រកណ្ដាល ។

សញ្ញាបត្រលេខ ២៣៩ ចុះកាលបរិច្ចេទដដែល តាំងលោកគ្រូ ចាប - អ៊ុម នាមធាយា សុវណ្ណប្បញ្ញត្ត កើតឆ្នាំខាល អាយុ ៤៧

វស្សា ២១ ជាចៅអធិការវត្តបូស្សីស្រស់ ឃុំច្បារអំពៅ ស្រុកកៀនស្វាយ
ខេត្រកណ្តាល ។

សញ្ញាប័ត្រលេខ ២៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ញឹក-ឃិម នាមធាយា សុវណ្ណកេសរ កើតឆ្នាំថោះ អាយុ ៥៨ វស្សា
៣៧ ជាចៅអធិការវត្តស្វាយរមៀត ឃុំក្តឿងរាយ ស្រុកកញ្ជ្រៀច
ខេត្រត្រៃវ៉ែង ។

សញ្ញាប័ត្រលេខ ២៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ប្រាជ្ញ-ឯម នាមធាយា ញាណរិសុទ្ធ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៥
ជាចៅអធិការវត្តត្រៃស្វាយ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្រត្រៃវ៉ែង ។

សញ្ញាប័ត្រលេខ ២៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
សុខ-មូល នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំរោង អាយុ ៦៩ វស្សា ៤៩
ជាចៅអធិការវត្តសំរោង ឃុំក្តឿងរាយ ស្រុកកញ្ជ្រៀច ខេត្រត្រៃវ៉ែង ។

សញ្ញាប័ត្រលេខ ២៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ចន្ទ-យ៉ា នាមធាយា ធម្មប្បញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ៩ ជា
ចៅអធិការវត្តចុងអំពិល ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្រត្រៃវ៉ែង ។

សញ្ញាប័ត្រលេខ ២៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
គល់-ឡាយ នាមធាយា ព្រហ្មកេសរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២២
ជាចៅអធិការវត្តកណ្តាល ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្រត្រៃវ៉ែង ។

សញ្ញាប័ត្រលេខ ២៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់-ប៊ុត នামធាយ បុស្សទេវ៉ៅ កើតឆ្នាំមមី អាយុ ៣១ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តចាន់ស្វាយ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្ត វៀតណាម ។

សញ្ញាប័ត្រលេខ ២៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី - យ៉ង់ នামធាយ បញ្ញាសកេ កើតឆ្នាំច អាយុ ២៧ វស្សា ៥ ជា គ្រូសូត្រធ្វើ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចៅ - តុប នামធាយ ចន្ទមង្គ្ល កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជា គ្រូសូត្រស្តាំ វត្តព្រៃកទ្រមាក់ ឃុំព្រៃកទ្រមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ២៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡុង - ឆេង នামធាយ ពុទ្ធប្បញ្ញា កើតឆ្នាំឆ្លូ អាយុ ៣៦ វស្សា ១២ ជាចៅអធិការវត្តកោងកាង ឃុំកោងកាង ស្រុកឆ្ការឡុង ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន - ដុម នামធាយ ឥន្ទប្បញ្ញា កើតឆ្នាំរកា អាយុ ៤០ វស្សា ១៩ ជាចៅអធិការ វត្តត្រពាំងឈូក ឃុំញ្ញាយ ស្រុកសំរោងទង ខេត្ត កំពង់ស្ពឺ ។

(មានត)

សូមជូនដំណឹង

....

ការផ្សាយរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលគាត់ខានបោះពុម្ពមកយូរហើយ ដោយខ្វះអក្សរ និងក្រដាស ឥឡូវនេះ ចាប់ផ្ដើមបោះពុម្ពបានឡើងវិញហើយ មានសៀវភៅគាណការៈ បាលី, សម្ពុទ្ធមាលា, បាដិមោក្ខសង្ខេប, ពិធីទ្វាទសមាសសង្ខេបជាភាសាបារាំងនិងរឿងមួយពាន់មួយយប់ជាដើម ដែលទើបនឹងចេញពីរោងពុម្ពក្នុងពេលថ្មីៗនេះ ហេតុនេះ បើអស់លោកអ្នកប្រាថ្នាចង់បានសៀវភៅដូចមានឈ្មោះខាងលើសូមអញ្ជើញចូលទៅជាវនៅក្រុមពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ

IMPRIMERIE ROYALE